September-2008.qxd 8/27/2008 9:43 AM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី២ ថ្ងៃទី០១-៣០ ខែកញ្ញា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ១៣

**មាតិកា**




បាត់ដំបង : កុមារក្រីក្រ និងកំព្រាទទួលការឧបត្ថម្ភ ទំព័រ ៧



CCAMH : ជួយកុមារដែលមានបញ្ហាសុខភាពផ្លូវចិត្ត ទំព័រ ៨



ភ្លេងពិណពាទ្យនឹងមានគ្រោះ ទំព័រ ១៤


# ការប្រឡងមធ្យមសិក្សាទុតិយភូមិ និងបញ្ហាត្រូវដោះស្រាយ

ទំព័រទី១០...




SIPAR
សៀវភៅ
ផ្ញើអោយអ្នកចេះ
មានលក់នៅតាមបណ្ណាគារ
និងតូបលក់សៀវភៅនានា
023 216 001
siparedition@online.com.kh



កម្មវិធីវិទ្យុ
អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: FM 102.5 Mhz ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:០០-១៣:០០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
កំពត : FM 92.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

September-2008.qxd 8/27/2008 9:43 AM Page 2

# រូបថតសម្រាប់លេខនេះ


Photo : L. Sovanna

ព្រះសង្ឃនិមន្តបិណ្ឌបាតក្នុងភូមិចំណុះជើងវត្ត ស្របនឹងក្បួនដង្ហែនៃពិធីបុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ កាលពីថ្ងៃទី១៧ ខែសីហា នៅបាត់ដំបង។ សកម្មភាពនេះសបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាពោរពេញដោយភាពសុខដុមរវាងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃសន្តិភាពសង្គម។ **(ឆ្វេង)**

លោកគីកេ ហ្វីការ៉េដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង និងលោកបូជាចារ្យតូតែត ធ្វើជាអធិបតីក្នុងក្បួនដង្ហែនៃពិធីបុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ។ **(ក្រោម)**

ពិធីហែព្រះនាងម៉ារីក្នុងឱកាសបុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខដែលមានការចូលរួមពីគ្រីស្តបរិស័ទយ៉ាងច្រើនកុះករមកពីព្រះសហគមន៍កាតូលិកនានា ដូចជា បាត់ដំបង តាហែន និងព្រះសហគមន៍កាតូលិកច្រាបវាល ដែលពិធីបុណ្យនេះប្រារព្ធធ្វើឡើង កាលពីថ្ងៃទី១៧ សីហា ឆ្នាំ២០០៨ កន្លងទៅ។ **(ក្រោម)**


Photo : L. Sovanna


Photo : L. Sovanna

បងស្រីជូនផ្កាក្នុងឱកាសខួបកំណើត គម្រប់៧៣ឆ្នាំ ចូល៧៤ឆ្នាំ នៃលោកអេមីល ដេតម្ប អភិបាលភូមិភាគភ្នំពេញ ថ្ងៃទី១៥ សីហា ឆ្នាំ២០០៨ នៅព្រះសហគមន៍សន្តយ៉ូសែប-ភ្នំពេញ **(ក្រោម)**


Photo : L. Sovanna

លោកមួង រស់ ជានិស្សិតទេវវិទ្យាល័យកម្ពុជា ត្រូវបានប្រារព្ធពិធីប្រកាសទទួលស្គាល់ ជានិស្សិតទេវវិទ្យាល័យសម្រាប់ព្រះសហគមន៍ភូមិភាគបាត់ដំបង និងពិធីបំពាក់អាវសបំពង់វែង ក្រោមអធិបតីភាពលោកគីកេ ជាអភិបាល កាលពីថ្ងៃទី១៧ សីហា។ **(ឆ្វេង)**


Photo : L. Samphors



# វិចារណកថា

## ការអប់រំនៅកម្ពុជា កំពុងមានភាពអសកម្មខ្លះ


Photo : P. Samphy

លោកបូជាចារ្យ អូមែរ ហ្សីរ៉ាល់ដូ ប្រធានមណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក (CSC)

ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងជាខ្លាំងដើម្បីកសាងនូវវិស័យអប់រំឡើងវិញ បន្ទាប់ពីត្រូវបំផ្លាញដល់ឫសគល់នៅក្នុងរបបខ្មែរក្រហម មានដូចជា សាលារៀន សម្ភារៈសិក្សា ឯកសារផ្សេងៗ-ល- មិនត្រឹមតែប៉ុណ្ណោះ អ្នកប្រាជ្ញ សាស្ត្រាចារ្យ លោកគ្រូ-អ្នកគ្រូ អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសជាច្រើននាក់ក៏ត្រូវបានសម្លាប់ទៀត ។

ក្រោយពីរបបខ្មែរក្រហមបានដួលរលំ ប្រព័ន្ធអប់រំ នៅកម្ពុជាចាប់ផ្តើមរស់រានមានជីវិតឡើងវិញ ។ កិច្ចការធំៗជាច្រើនត្រូវបានបំពេញចេញជាលទ្ធផលយ៉ាងល្អ ជាមួយនិងឆន្ទៈមោះមុតរបស់ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលខ្មែរ ។

ទោះជាយ៉ាងណា សព្វថ្ងៃនេះ ប្រទេសកម្ពុជាក៏កំពុងប្រឈមមុខជាមួយនិងឧបសគ្គយ៉ាងធ្ងន់ធ្ងរ នៅក្នុងវិស័យសិក្សាធិការនេះផងដែរ រួមមាន អសមត្ថភាពរបស់បុគ្គលិកខ្លះៗ ប្រាក់ខែទាប កង្វះខាតនូវសម្ភារៈសិក្សា និងសាលារៀនជាដើម ។ ស្ថិតក្នុងបរិបទនេះហើយដែលអំពើពុករលួយខ្លះៗបានកើតឡើង ។ តួយ៉ាងក្នុងការប្រឡងមធ្យមសិក្សា សម្រាប់សិស្សថ្នាក់ទី១២ កាលពីខែសីហាកន្លងទៅ សិស្សមួយចំនួនបានទិញវិញ្ញាសាមុនប្រឡង ។ ខ្លះទៀតបានចំណាយលុយឱ្យអនុរក្សដើម្បីអាចលបមើលគ្នា ឬមើលឯកសារជាដើម ។ ទាំងនេះជាជំងឺសង្គមមួយនៅក្នុងវិស័យអប់រំ ដែលយើងទាំងអស់គ្នា ត្រូវចូលរួមគិតគូរ និងដោះស្រាយប្រកបដោយមនសិការជាតិខ្ពស់ ។

ព្រះសហគមន៍កាតូលិក បានចូលរួមអភិវឌ្ឍន៍វិស័យអប់រំ នៅកម្ពុជាដោយផ្ទាល់ និងប្រយោល រយៈពេលជិត ៣ ទសវត្សរ៍រួចមកហើយ ។ តាមរយៈការខិតខំប្រឹងប្រែងកន្លងមក យើងអាចរៀបរាប់ រួមមានការបើកសាលារៀន និងមត្តេយ្យក្នុងទីក្រុង ទីប្រជុំជន ឬនៅតាមជនបទដាច់ស្រយាល ដូចជាវិទ្យាល័យ និងវិទ្យាស្ថានឯកទេសកសិកម្មសន្តហ្វ្រង់ស្វ័រ នៅឯខេត្តតាកែវដឹកនាំដោយលោកបូជាចារ្យអូលីវីយេ ឬសាលាឡាវ៉ាឡាដំណើរការដោយក្រុមបងប្រុសគោរពព្រះនាងម៉ារី-ល- ។ ទាំងនេះជាការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នា ៕


**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្សីរ៉ាល់ដូ ។

ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា ។

Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧



**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៌នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ បើប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងលេខទូរស័ព្ទ : ០១២ ២៤៤ ៧៧៨៕


## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក


**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៩៦០៕


**សារសម្រាប់មិត្តអ្នកអាន!**

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



**សូមប្រិយមិត្តមើល និងកំសាន្តជាមួយល្បែងរូបភាព នៅទំព័រទី១៦ រួចទើបមើលចម្លើយនេះ។**


**សេចក្តីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយចំណេញបានច្រើន សូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។ បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ៕

September-2008.qxd 8/27/2008 9:44 AM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

### ថ្ងៃអាទិត្យ ទី២៣ នៃរដូវធម្មតា (ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៨)

*(ម៉ាថាយ១៨,១៥-២០)* ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ បាននាំឱ្យយើងជាគ្រីស្តបរិស័ទយល់ថា ការសម្រុះសម្រួលមិនមែនធ្វើតាមអំពើយើងទេ ប៉ុន្តែតាមរយៈពាក្យសំដីយើង។ យើងមានទំនួលខុសត្រូវជួយអ្នកដទៃឱ្យកែប្រែអាកប្បកិរិយា និងសម្រួលអំពើបាបបងប្អូន។ យើងជួយសម្រួលបងប្អូន ក្នុងនាមព្រះយេស៊ូគ្រីស្ត និងព្រះសហគមន៍។ ប៉ុន្តែដើម្បីសម្រុះសម្រួល និងសង្គ្រោះអ្នកដទៃបាន យើងក៏ត្រូវតែពង្រឹងជំនឿយើងលើព្រះជាម្ចាស់ ដោយអធិដ្ឋាន និងហ្វឹកហ្វឺនខាងជំនឿឱ្យបានគ្រប់ពេលវេលាផងដែរ។

### ថ្ងៃអាទិត្យ ទី២៤ នៃរដូវធម្មតា (ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៨)

*(ម៉ាថាយ១៨,២១-៣៥)* ឱ! ព្រះអម្ចាស់ បើបងប្អូនចេះតែប្រព្រឹត្តអំពើបាបមកលើទូលបង្គំ តើទូលបង្គំត្រូវអត់ទោសឱ្យគេប៉ុន្មានដង? លោកសិលាទូលព្រះយេស៊ូដូច្នេះថា និងមានមនុស្សជាច្រើនក៏បានសួរខ្លួនឯងថា តើពេលណាទើបពួកគេធ្វើដូច្នេះដែរ?។ ព្រះបន្ទូលដំណឹងល្អនៅថ្ងៃនេះ នាំឱ្យយើងដឹងថា ការអត់ទោសឱ្យអ្នកដទៃពិតជាមិនអាចទៅរួចបានទេ ប្រសិនបើពួកយើងមិនមានចិត្តអត់ទោសឱ្យគេនោះ។ ព្រះយេស៊ូមានព្រះបន្ទូលថា: "ខ្ញុំសូមប្រាប់ថា អ្នកត្រូវអត់ទោសឱ្យគេ ពុំមែនចិតសិបប្រាំពីរដង (៧៧) នោះទេ ត្រូវអត់ទោសឱ្យគេចិតសិប-ប្រាំពីរដង(៧០គុណ៧ដង)" ... វាមានន័យថា យើងត្រូវត្រៀមខ្លួនអត់ទោសឱ្យគេ ដូចព្រះយេស៊ូអត់ទោសយើងដែរ។ សម្រាប់គ្រីស្តបរិស័ទ ការអត់អោនទោសមិនមានព្រំដែនកំណត់ទេ។ តាមធម្មជាតិ មនុស្សមានចិត្តខឹងសម្បារ។ ការអត់ទោសឱ្យដល់អ្នកដែលមើលងាយខ្លួន មិនមែនងាយស្រួលនៃចរិតមនុស្សពីធម្មជាតិ ប៉ុន្តែព្រះហឫទ័យព្រះជាម្ចាស់អត់ទោសឱ្យអ្នកនោះ។ តើយើងដាក់ចិត្តអត់ទោសឱ្យអ្នកដទៃរបៀបណា? មធ្យោបាយតែមួយគត់ និងមានប្រសិទ្ធភាព គឺការហ្វឹកហ្វឺនខាងវិញ្ញាណដើម្បីយល់អំពីធមិមេត្តាករុណារបស់ព្រះជាម្ចាស់។

### ថ្ងៃអាទិត្យ ទី២៥ នៃរដូវធម្មតា (ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៨)

*(ម៉ាថាយ ២០,១-១៦)* ក្នុងសង្គមសព្វថ្ងៃ មានអំពើអយុត្តិធមិជាច្រើនដូចជា មនុស្សតិចតួចណាស់ដែលមានប្រាក់ខែខ្ពស់ តែមានមនុស្សភាគច្រើនទទួលបានប្រាក់ខែទាបបំផុត ហើយស្ទើរតែគ្មានប្រាក់ខែទៀតផង។ ពេលយើងស្តាប់ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ យើងគិតថាព្រះយេស៊ូយល់ស្របនឹងអំពើអយុត្តិធមិក្នុងសង្គម។ ការពិតនោះ ប្រសិនយើងបានអានព្រះបន្ទូលប្រុងប្រយ័ត្ន យើងឃើញថាព្រះយេស៊ូ ចង់បង្រៀនយើងឱ្យមានចិត្តមេត្តាករុណាដល់អ្នកដទៃ។ តើអ្នកមានអាយុប៉ុន្មាន? តើអ្នកបានត្រៀមខ្លួនសម្រាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ឬនៅ? យើងត្រូវជឿជាក់លើខ្លួនឯងថា ព្រះជាម្ចាស់ នឹងឱ្យប្រាក់ខែដ៏យុត្តិ-ធមិដល់យើង ទោះបីយើងធ្វើការនៅចុងម៉ោងក៏ដោយ។

### ថ្ងៃអាទិត្យ ទី២៦ នៃរដូវធម្មតា (ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៨)

*(ម៉ាថាយ២១,២៨-៣២)* តើបងប្អូនឃើញបំណងព្រះជាម្ចាស់ក្នុងជីវិតដោយរបៀបណា? តើបងប្អូនដើរតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងជីវិតរបៀបណា? ក្នុងចំណោមកូនទាំងពីរ តើកូនណាបានធ្វើតាមបំណងរបស់ឪពុក? ព្រះយេស៊ូសួរដូច្នេះបន្ទាប់ពីនិទានអំពីរឿងកូនពីរនាក់ដែលមានឪពុកធ្វើការនៅចំការទំពាំងបាយជូរ។ កូនច្បងបានបដិសេធមិនទៅចំការ ប៉ុន្តែក្រោយមកកូននោះដូរគំនិត ហើយក៏ទៅចំការ។ ចំណែកកូនពៅវិញ បានយល់ព្រមទៅធ្វើការនៅចំការតែអត់ទៅទេ។ បងប្អូនដែលបានស្តាប់រឿងនេះបានយល់ស្របនឹងព្រះជាម្ចាស់ថា អ្នកដែលធ្វើតាមបំណងរបស់ឪពុក គឺកូនច្បងនិយាយថា ទេ ! ប៉ុន្តែក្រោយមកទៅ។ ព្រះយេស៊ូបានបញ្ជាក់ថា មានមនុស្សជាច្រើនបដិសេធព្រះរាជ្យព្រះជាម្ចាស់ដូច្នេះ ប៉ុន្តែនៅក្នុងចិត្តរបស់បងប្អូនពេញដោយសេចក្តីស្រលាញ់ និងការទទួលស្គាល់ព្រះជាម្ចាស់។
ពេលនេះ ព្រះយេស៊ូលើកឧទាហរណ៍មួយអំពីអ្នកយកពន្ធ និងស្រីពេស្យា ដែលអាចទៅកាន់ព្រះរាជ្យព្រះជាម្ចាស់មុនមនុស្សឯទៀតៗ ដែលពេញចិត្តជម្រើសកូនពៅ ដែលនិយាយថាទៅ តែក្រោយមកអត់ទៅ។ តាមរយៈរឿងនេះ មានមនុស្សជាច្រើនក៏មានករណីនេះដែរ ដែលនិយាយថា បាទ ឬចាស! ចំពោះព្រះជាម្ចាស់ តែក្រោយមក ធ្វើតែតាមចិត្តខ្លួនឯង មិនមែនតាមព្រះហឫទ័យព្រះជាម្ចាស់ឡើយ ៕

*(អ្នកនាំសារ ខែកញ្ញា ២០០៨ - អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ / លោកឪពុក អ្វូមែរ ហ្វ៊ីរ៉ាល់ដូ)*

## សម្រាប់កុមារ



Photo: DR

### ប្រវត្តិសន្តប៉ូល

អ្នកនាំសារ លេខនេះ សូមបង្ហាញប្អូនៗ នូវប្រវត្តិរបស់សន្តប៉ូល ដោយសារឆ្នាំនេះព្រះសហគមន៍កាតូលិកគោរពជាឆ្នាំនៃសន្តប៉ូល។

**តើសន្តប៉ូលមានកំណើតនៅស្រុកណា? តើលោកជាជនជាតិអ្វី?**

លោកប៉ូលកើតនៅទីក្រុងតាសុស ស្រុកស៊ីលីស៊ី។ លោកប៉ូលជាជនជាតិយូដា ហើយលោកមានសញ្ជាតិរ៉ូម៉ាំងផងដែរ។ លោកបានទទួលការអប់រំតាមវិន័យរបស់ជនជាតិយូដា យ៉ាងតឹងរ៉ឹងពីសំណាក់លោកកាម៉ាលីអែល។

ក្រោយមកលោកជាអ្នកដែលទទួលបន្ទុកក្នុងការប្រព្រឹត្តអំពើបៀតបៀនទៅលើគ្រីស្តបរិស័ទផងដែរ។ លោកមានឈ្មោះដើមថា "សូល"។

**តើលោកប៉ូលក្លាយជាសាវ័ករបស់ព្រះយេស៊ូដោយរបៀបណា?**

លោកប៉ូលបានបៀតបៀនគ្រីស្តបរិស័ទយ៉ាងខ្លាំង ហើយសម្លាប់គ្រីស្តបរិស័ទទៀតផងដែរ។ លោកបានសុំលិខិតអនុញ្ញាតចូលទៅក្នុងសាលាប្រជុំនានាក្នុងក្រុងដាម៉ាស ក្រែងរកឃើញអ្នកខ្លះនៅទីនោះ ដែលដើរតាមមាគ៌ារបស់ព្រះអម្ចាស់។ ទោះជាប្រុសក្តី ឬស្រីក្តី លោកនឹងចាប់ពួកគេយកមកក្រុងយេរូសាឡឹមទាំងអស់។

ប៉ុន្តែពេលធ្វើដំណើរទៅក្រុងដាម៉ាស នាពាក់កណ្តាលផ្លូវ ស្រាប់តែមានពន្លឺចាំងពីផ្ទៃមេឃមកព័ទ្ធជុំវិញគាត់ រួចធ្វើឱ្យគាត់ដួល។ ក្នុងពន្លឺមានសម្លេង ហៅឈ្មោះរបស់គាត់ថា "សូល! ហេតុអ្វីអ្នកមកបៀតបៀនខ្ញុំ"។ លោកសួរទៅសម្លេងនោះថា "ជាអ្នកណា?"។ សម្លេងនោះឆ្លើយតបវិញថា "ខ្ញុំជាយេស៊ូ!"។ ក្រោយមកធ្វើឱ្យភ្នែករបស់លោកមើលអ្វីមិនឃើញ។ តាមរយៈសម្លេងនេះ ព្រះយេស៊ូបានចាត់គាត់ចូលទៅក្នុងក្រុងដាម៉ាសជួបនឹងសាវ័កម្នាក់ឈ្មោះអណាញ៉ាស។ សាវ័កនោះបានធ្វើឱ្យភ្នែករបស់លោកបានជាសះស្បើយ។ លោកចាប់ផ្តើមកែប្រែចិត្តគំនិតចាប់ពេលនោះទៅ។ លោកបានប្តូរឈ្មោះពី "សូលទៅជាប៉ូលវិញ" ហើយក៏បានក្លាយជាគ្រីស្តទូតម្នាក់ក្នុងចំណោមគ្រីស្តទូតទាំង១២ របស់ព្រះយេស៊ូទៀតផង៕

លី សុវណ្ណា



# ព្រឹត្តិការណ៍ប្រចាំខែ



Photo: R. Dina

## ឯកឧត្តមហោ ណាំហុង: "កិច្ចប្រជុំជម្លោះព្រំដែនខ្មែរ និងថៃទៅមុខដូចរ៉ូឡូកិនផ្លូវ"

ក្នុងដំណើរវិលត្រឡប់ពីកិច្ចប្រជុំ នៅក្រុងហួហ៊ីន ប្រទេសថៃ កាលពីថ្ងៃពុធ ទី២០ សីហា រដ្ឋមន្ត្រីការទូតខ្មែរ ឯកឧត្តមហោ ណាំហុង បានប្រដូចការចរចាពីបញ្ហាប្រាសាទព្រះវិហារលើកទី២ នេះ មានចលនាដូចជារ៉ូឡូកិនផ្លូវ គឺទោះជាមានឧបសគ្គបន្តិចបន្តួចក៏ដោយ ក៏វានៅទៅមុខដែរ។ បើតាមប្រសាសន៍របស់ឯកឧត្តម កិច្ចប្រជុំទ្វេភាគីកម្ពុជា-ថៃ លើកនេះ បានសម្រេចឱ្យមានការជួបចរចាចំនួនពីរទៀត គឺភាគីទាំងពីរបានព្រមព្រៀងគ្នាឱ្យក្រុមការងារពិសេស Tash-Force របស់កម្ពុជា ធ្វើការជាមួយមេបញ្ជាការថ្នាក់ភូមិភាគថៃ ដើម្បីឈានទៅដកកងទ័ពជាស្ថាពរនៅក្នុងបរិវេណវត្តកែវសិក្ខាគិរីស្វារៈ។ ជំនួបនេះគ្រោងនឹងធ្វើនៅថ្ងៃទី២៩ សីហានៅខេត្តសៀមរាប។ ដោយឡែកគណៈកម្មាធិការព្រំដែនចម្រុះនៃប្រទេសទាំងពីរ គ្រោងនឹងចរចាគ្នារឿងវិវាទព្រំដែន នៅខែតុលាខាងមុខ ដោយផ្តោតចម្បងលើតំបន់ទំនាស់ព្រំដែនរួម និងការដោះមីនដើម្បីវាស់វែងព្រំដែន។ សម្រាប់ករណីប្រាសាទតាមាន់ធំ និងតាមាន់តូច មិនត្រូវបានគេលើកយកមកពិភាក្សានៅហួហ៊ីនទេ ដោយគេនឹងជជែករឿងនេះក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសលើកក្រោយ។

## បាតុកម្មប្រឆាំងថៃឈ្លានពានព្រះវិហារត្រូវរាំងខ្ទប់

បាតុកម្មទាមទារឱ្យដកកងទ័ពថៃឈ្លានពានចេញពីវត្តកែវសិក្ខាគិរីស្វារៈនៃប្រាសាទព្រះវិហារ ដែលដឹកនាំដោយសមាគមគ្រូបង្រៀនឯករាជ្យ និងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃអាទិត្យ ទី១៧ សីហា ត្រូវរាំងខ្ទប់ដោយកងកម្លាំងនគរបាលក្រុងភ្នំពេញរាប់រយនាក់ដែលបានដាក់ពង្រាយគ្រប់ច្រកល្ហក។ ក្បួនបាតុកម្ម ដែលគ្រោងដង្ហែចេញពីសួនច្បារមុខអគាររដ្ឋសភាចាស់ឆ្ពោះទៅស្ថានទូតថៃ និងវិថីនានាក្នុងក្រុងត្រូវរំសាយ ហើយការវិលមកធ្វើនៅមុខទីស្នាក់ការរបស់ខ្លួនឯខណ្ឌចំការមនក៏ត្រូវបង្ក្រាបដល់ទ្វាររបង។ ការបង្ក្រាបនេះត្រូវបានអាជ្ញាធរ សំអាងថា បាតុកម្មគ្មានច្បាប់អនុញ្ញាត។

## កាសែត The Mekong Time បាយ បាយ ហើយ

កាសែតប្រចាំថ្ងៃភាសាអង់គ្លេស The Mekong Time បានបិទទ្វារជាផ្លូវការហើយ នៅថ្ងៃច័ន្ទ ១៨ សីហា នេះ ក្រោយពីបានបោះពុម្ពផ្សាយអស់រយៈពេលជិតប្រាំមួយខែចាប់ពីខែកុម្ភៈមក។ លោកនេត ភត្រា និពន្ធនាយកកាសែត The Mekong Time បាននិយាយថា ការបិទទ្វារនេះមកពីមូលហេតុថវិកា ព្រោះម្ចាស់ជំនួយមិនផ្តល់ជំនួយបន្តទៀតឡើយ។ បើតាមការបញ្ជាក់របស់និពន្ធនាយកកាសែតរូបនេះ ថវិកាដែលប្រមូលបានពីការលក់ មានត្រឹមតែមួយភាគបីនៃការចំណាយលើប្រាក់ខែបុគ្គលិកតែប៉ុណ្ណោះ។ កាសែត The Mekong Time បានប្រកាសបិទទ្វារ ក្រោយពេលគូប្រជែងរបស់ខ្លួនគឺកាសែត Phnom Penh Post បានប្តូរការចេញផ្សាយរបស់ខ្លួនពីកាសែតប្រចាំសប្តាហ៍ មកជាកាសែតប្រចាំថ្ងៃ ដែលមានអាយុទើបតែដប់ថ្ងៃ តែប៉ុណ្ណោះ ៕

រស់ ឌីណា

## កងទ័ពរបស់រុស្ស៊ីសម្រុកចូលលុកលុយប្រទេសហ្សកហ្ស៊ី



Photo: DR

កងទ័ពរុស្ស៊ីបានត្រូវគេរាយការណ៍ថា បានបើកការវាយប្រហារចូលទៅលើទឹកដីប្រទេសហ្សកហ្ស៊ីកាលពីថ្ងៃទី៨ សីហា ឆ្នាំ២០០៨ ក្រោយពេលដែលកងទ័ពប្រទេសហ្សកហ្ស៊ី បើកការវាយប្រហារចូលទៅក្នុងតំបន់អូសេទីខាងត្បូង ដែលជាតំបន់បំបែកខ្លួនស្និទ្ធនឹងប្រទេសរុស្ស៊ីកាលពីថ្ងៃទី៧ ខែសីហា។
បើតាមសារព័ត៌មានអេភីឱ្យដឹងថា មកដល់ថ្ងៃទី១២ ខែសីហា កងទ័ពរុស្ស៊ីរាប់ពាន់នាក់ អមដោយយានចម្បាំងប្រមាណ ១៣៥គ្រឿង មានទាំងរថក្រោះ និងយន្តហោះ បានសម្រុកចូល និងធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ពសំខាន់ៗមួយចំនួន នៅក្នុងប្រទេសហ្សកហ្ស៊ី។
គេបានរាយការណ៍ថា ការវាយលុករបស់រុស្ស៊ីចូលក្នុងប្រទេសហ្សកហ្ស៊ីនេះបានសម្លាប់ជីវិតមនុស្សប្រមាណជា ២០០០នាក់រួចហើយ តែចំនួនពិតប្រាកដអាចមានច្រើនជាងនេះ ហើយមានមនុស្សរាប់ពាន់នាក់ បានភៀសខ្លួនចេញពីតំបន់ទទួលរងវាយប្រហារ។
ក្នុងការលុកលុយនេះ រុស្ស៊ីទាមទារឱ្យប្រធានាធិបតីហ្សកហ្ស៊ី ស្និទ្ធនឹងលោកខាងលិចលាលែងតំណែង និងឱ្យកងទ័ពហ្សកហ្ស៊ីដកចេញពីទឹកដីអូសេទីខាងត្បូង និងតំបន់អាប់ខាស៊ី ៕

## សម្បត្តិ ១៩ពាន់លានដុល្លាររបស់លោកថាក់ស៊ីននឹងត្រូវរឹបអូស

បន្ទាប់ពីបានស្វែងរកសិទ្ធិជ្រកកោនខាងនយោបាយ ក្នុងប្រទេសអង់គ្លេស ក្រោយពេលដែលតុលាការថៃបញ្ជាឱ្យចាប់ខ្លួនកាលពីដើមខែសីហារួចមក ទ្រព្យសម្បត្តិដែលមានតម្លៃ ៧៦ពាន់លានបាត ឬក៏ប្រហាក់ប្រហែលនឹង ១៩ពាន់លានដុល្លាររបស់លោក-ថាក់ស៊ីន ស៊ីណាវ៉ាត្រា នឹងត្រូវរឹបអូស។
តាមសារព័ត៌មានស៊ីនហួរ របស់ចិនក៏បានឱ្យដឹងថា តុលាការក្នុងប្រទេសថៃអាចនឹងបញ្ជាឱ្យគេធ្វើការរឹបអូសទ្រព្យសម្បត្តិរបស់លោកថាក់ស៊ីនចំនួនខាងលើ ក្នុងរយៈពេល ១សប្តាហ៍ទៀត។
ប្រភពដដែលនោះបានឱ្យដឹងថា មូលហេតុដែលឈានដល់ការរឹបអូសនេះ គឺនៅក្រោមបទចោទប្រកាន់ការប្រើអំណាចខុសគោលការណ៍ ពេលដែលលោកថាក់ស៊ីននៅធ្វើជានាយករដ្ឋមន្ត្រី។
បច្ចុប្បន្ននេះ ទ្រព្យសម្បត្តិលោកថាក់ស៊ីននៅគណនីធនាគារទាំង ១៦ក្នុងប្រទេសថៃត្រូវបានព្យួរចាប់តាំងពីលោកត្រូវបានគេទម្លាក់ដោយរដ្ឋប្រហារយោធាមកម្ល៉េះ។ នាពេលនេះ លោកនិងគ្រួសារកំពុងតែស្នាក់នៅក្នុងប្រទេសអង់គ្លេស ទោះបីអាជ្ញាធរថៃអះអាងថានឹងស្វែងរកការធ្វើបត្យាប័នដើម្បីនាំខ្លួនលោកមកកាត់ទោសក៏ដោយ ៕

ខាន់ ភិរម្យ

September-2008.qxd 8/27/2008 9:44 AM Page 6



# បងស្រីសេស៊ីលីយ៉ា នៃព្រះឈើឆ្កាង ប្រកាសពាក្យសច្ចា

**កែវ កញ្ញា**

បងស្រីសេស៊ីលីយ៉ានៃព្រះឈើឆ្កាង ធ្វើពិធីប្រកាសពាក្យសច្ចា ជាលើកដំបូង នៅក្នុងក្រុមគ្រួសារដូនជីសម្ងាត់កាមែល កាលពីថ្ងៃទី១៥ សីហា ឆ្នាំ២០០៨ នៅព្រះវិហារសន្តយ៉ូសែប រាជធានីភ្នំពេញ ក្រោមអធិបតីភាពរបស់លោកអភិបាល ភូមិភាគភ្នំពេញ អេមីល ដេតម្ប លោកអន់តូនីសាមី ស៊ូសៃរាជ ជាអភិបាលនៃភូមិភាគកំពង់ចាម លោកឪពុក បងស្រីនិងគ្រីស្តបរិស័ទចូលរួមប្រមាណជាង ២០០នាក់។ អ្នកស្រីអានីស៊ី ថាំងហ៊ីស្សា អាយុ ៥៤ឆ្នាំ ជាម្តាយរបស់បងស្រីសេស៊ីលីយ៉ា បានមានប្រសាសន៍ថា : "ខ្ញុំមិនដឹងជាត្រូវនិយាយយ៉ាងណាឡើយ នៅពេលដែលបានឃើញគេរៀបចំពីធីនេះឡើង ដោយមានទាំងលោកអភិបាល បូជាចារ្យ ក៏ដូចជាគ្រីស្តបរិស័ទមកចូលរួមយ៉ាងច្រើនកុះករដូចនេះ។ ដោយមានការគាំទ្រ ចំពោះផ្លូវជីវិតរបស់កូន អ្នកម្តាយរូបនេះ ក៏បានរំឭកអំពីការស្នើសុំរបស់កូនស្រីគាត់ពីដំបូងថា : "ពេលកូនមកប្រាប់ខ្ញុំ សុំចូលបួសជាដូនជីសម្ងាត់នោះ ធ្វើឱ្យអារម្មណ៍ខ្ញុំ ហាក់ដូចជាមេឃក្រឡាប់ចាក់អ៊ីចឹង។ ខ្ញុំក៏មិនដឹងត្រូវធ្វើយ៉ាងម៉េចទេ។ ខ្ញុំមានតែអធិដ្ឋាន និងគាំទ្រផ្លូវរបស់កូនដើម្បីឱ្យគេអាចរកផ្លូវសុភមង្គលក្នុងជីវិត និងមានសន្តិភាពក្នុងចិត្តជាមួយមាតាព្រះជាម្ចាស់"៕



Photo: L. Samphors

បងស្រីសេស៊ីលីយ៉ា នៃព្រះឈើឆ្កាង ក្រុមដូនជីសម្ងាត់ និងម្តាយរបស់បងស្រីក្នុងពេលហែតង្វាយនៃពិធីសច្ចាប្រណិធានចំពោះព្រះជាម្ចាស់

## សិក្ខាសាលាស្តីអំពីប្រយោជន៍សារព័ត៌មាន

យុវជនមកពីព្រះសហគមន៍កាតូលិក និងអង្គការនានា ប្រមាណ ២៥នាក់ បានចូលរួមក្នុងសិក្ខាសាលាមួយស្តីអំពីសារៈប្រយោជន៍នៃសារពត៌មាន ណែនាំដោយការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក។ អង្គសិក្ខាសាលានេះ ប្រារព្ធឡើងចាប់ពីថ្ងៃទី១១-១៥ ខែសីហា ឆ្នាំ២០០៨ នៅក្នុងព្រះសហគមន៍កាតូលិក ខេត្តបាត់ដំបង។



Photo : L. Sovanna

លោកបូជាចារ្យតូតែត បានីណល ជាអ្នកផ្តួចផ្តើមបង្កើតសិក្ខាសាលានេះ មានប្រសាសន៍ថា : "គោលដៅសំខាន់ក្នុងការបង្កើតសិក្ខាសាលានេះ មានបីចំនុច គឺចង់ផ្តល់ជំនាញថ្មី ផ្តល់ឱកាសឱ្យស្គាល់អំពីចំនុចខ្សោយ និងខ្លាំង និងពង្រីកទេពកោសល្យរបស់យុវជនផ្ទាល់។ ហើយយុវជនចូលរួមត្រូវតែមានអាយុ ១៦ឡើងទៅ"។ យុវជនទួន គឹមលី អាយុ២១ឆ្នាំ មកពីព្រះសហគមន៍តាពូង និយាយថា : "លោកទទួលបានគន្លឹះល្អៗ ជាច្រើនសម្រាប់អនុវត្តន៍លើផ្នែកសរសេរព័ត៌មាន តាមរយៈសិក្ខាសាលានេះដើម្បីចូលរួមអភិវឌ្ឍព្រះសហគមន៍"៕

**បាត់ដំបង : ភិរម្យ សុគន្ធា សារ៉េត សៅ**

## មណ្ឌលសុខភាពជួយអ្នកជំងឺដោយឥតបង់ថ្លៃ

មណ្ឌលសុខភាពព្រះសហគមន៍កាតូលិក បាត់ដំបង ឬហៅថា ពេទ្យយាយជី នៅខេត្តបាត់ដំបង ទទួលការព្យាបាលជំងឺជូនអ្នកក្រីក្រដោយឥតគិតថ្លៃ។ លោកនេន ព្រះនាមអ៊ុកចាន់ណា មានព្រះជន្ម ១៤ ព្រះវស្សា មកពីស្រុកសិរីសោភ័ណ ខេត្តបន្ទាយ-មានជ័យ មានសង្ឃដីកាឱ្យដឹងថា : "អាត្មាបានមកសម្រាកព្យាបាលនៅទីនេះ ១០ថ្ងៃហើយ ដោយ-សារជំងឺខ្វះឈាម តែពេលនេះអាត្មាបានធូរស្បើយហើយ។" ព្រះអង្គបន្តថា គ្រួសាររបស់លោកក្រីក្រណាស់ ទើបលោកមកទទួលការព្យាបាលនៅទីនេះ ហើយលោកក៏គ្មានបង់ប្រាក់អ្វីឡើយ។ រីឯគ្រូពេទ្យវិញមានភាពរួសរាយរាក់ទាក់ ថែមទាំងពិនិត្យនិងព្យាបាលបានត្រឹមត្រូវទៀតផង។ ដោយឡែកបងស្រីម៉ារី ហ្សង់ណេអាត អ្នកគ្រប់-គ្រងមណ្ឌលសុខភាពកាតូលិកបាត់ដំបង បានសង្កត់ធ្ងន់លើចំនុចនេះថា: "ទង្វើទាំងនេះបង្ហាញឱ្យឃើញថា យើងជាសាក្សីនៃព្រះជាម្ចាស់ អំពីការសង្គ្រោះ និងចិត្តមេត្តាករុណារបស់ព្រះអង្គ"។ មណ្ឌលនេះបង្កើតនាឆ្នាំ២០០០ មានបុគ្គលិកបម្រើការងារ៥នាក់។ ក្នុងមួយឆ្នាំៗ មណ្ឌលត្រូវចំណាយទឹកប្រាក់ពី២៥០០០ដុល្លារ ដល់៣០០០០ដុល្លារ៕

**បាត់ដំបង : សៅ សូធី អ៊ំ សុគង់ អ៊ួង ឡឿន**

## សិក្ខាសាលាអំពីការប្រឆាំងអំពើហិង្សា ធ្វើនៅតាពូង

កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៨នេះ ព្រះសហគមន៍កាតូលិកតាពូង ភូមិភាគបាត់ដំបង បានរៀបចំសិក្ខាសាលាមួយ ស្តីអំពីការប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ដែលមានប្រជាជនចំនួន ២២នាក់ ចូលរួម ជាមួយនិងការណែនាំពីនិស្សិត ៦នាក់ ដែលមកពីទីក្រុងភ្នំពេញ។ និស្សិតថុង ថន អាយុ ២៣ឆ្នាំ អ្នកណែនាំអង្គសិក្ខាសាលា និយាយថា : "ការបើកអង្គសិក្ខា-សាលានេះ គឺដើម្បីជួយឱ្យបងប្អូននៅទីជនបទឱ្យយល់ច្បាស់ថា អ្វីទៅជាអំពើហិង្សា? ហើយពួកគាត់គួរជៀសវាងយ៉ាងដូចម្តេច?" អ្នកស្រីខាំថង ដែលជាគណៈកម្មការរបស់ព្រះសហគមន៍តាពូង មានប្រសាសន៍ថា : "ប្រជា-ជនគួរតែយល់ឱ្យច្បាស់ អំពីទំនាក់ទំនងបុរសនិងស្ត្រី ដើម្បីជៀសវាងនូវអំពើហិង្សានៅក្នុងគ្រួសារដែលជួបប្រទះរាល់ថ្ងៃ។ ពួកគេគួរតែមកស្វែងយល់អំពីអំពើហិង្សានេះដែរ ពីព្រោះវាជាឱកាសទីមួយ ដែលមាននិស្សិតស្ម័គ្រចិត្តមកបង្ហាត់បង្រៀនដូចនេះ"។ យុវជនទូច ពិនសុផល ជាសិក្ខាកាមបានឱ្យដឹងថា : "ខ្ញុំសោកស្តាយណាស់ ដោយមានតែនារីចូលរួម។ បើមានបុរសច្រើនគឺល្អ ពីព្រោះអំពើហិង្សានេះច្រើនបង្កឡើងដោយសារបុរស"៕

**បាត់ដំបង : ទូច ផារី ម៉ានរីខាន**





# បាត់ដំបង : កុមារក្រីក្រ និងកំព្រា ទទួលការឧបត្ថម្ភ

**សោភ័ណ សារ៉ាត់ គឹមស៊ូ វ៉ៃន**

កុមារក្រីក្រ អនាថា និងកំព្រា ប្រមាណជាង ២០០នាក់ អាយុចាប់ពី៧ឆ្នាំ ដល់១៥ឆ្នាំ មកពីភូមិនានានៃទីរួមខេត្តបាត់ដំបង បានមកជួបជុំគ្នា ក្នុងកម្មវិធីមួយដែលមានឈ្មោះថា "សាំមើខេម" (**Summer Camp**) នៅក្នុងទីបរិវេណព្រះសហគមន៍កាតូលិកបាត់ដំបង។ កម្មវិធីនេះរៀបចំដោយយុវជន មកពីប្រទេសអេស្ប៉ាញ ធ្វើកិច្ចសហប្រតិបត្តិការជាមួយយុវជននៃព្រះសហគមន៍កាតូលិក តំបន់បាត់ដំបង ពីថ្ងៃទី២៨ កក្កដា ដល់ទី១៥ សីហា កន្លងទៅ។ លោកហ្គុនសាឡូ ហ្វីហ្គារ៉េដូ (ភូមី) អ្នកដឹកនាំក្រុមយុវជនអេស្ប៉ាញ បញ្ជាក់ពីគោលបំណងនៃកម្មវិធីនេះថា: "ទីមួយ គឺផ្តល់អាហារ សម្លៀកបំពាក់ ការអប់រំ និងលេងល្បែងកំសាន្ត។ ទីពីរ គឺចង់ដឹងថាតើក្រុមក្មេងៗបានចូលសាលារៀនឬទេ? ហើយក្រុមគ្រួសារ ពួកគេមានជីវភាពយ៉ាងណាដែរ។ យុវវ័យ ២៥ឆ្នាំ រូបនេះ បានបន្ថែមទៀតថា : "ទាំងអស់គ្នាមានអារម្មណ៍សប្បាយរីករាយណាស់ នាពេលដែលបំពេញការងារនេះជាមួយក្មេងៗ"។ ចំណែកយុវនារីស៊ីម សំអាន ជាអ្នកសម្របសម្រួលក្នុងកម្មវិធីតំណាង ឱ្យក្រុមយុវជនកាតូលិកកម្ពុជាក៏បានបញ្ជាក់ថា កម្មវិធីនេះបង្កើតឡើងឆ្នាំ២០០៥ ដោយការផ្តើមគំនិតពីលោកអាល់វ៉ារ៉ូ ហ្វីហ្គារ៉េដូជាបងប្រុសបង្កើតរបស់ភូមី ក្នុងពេលដែលលោកមកបម្រើការងារនៅបាត់ដំបងក្នុងនាមអ្នកស្ម័គ្រចិត្ត។ កុមារម្នាក់ៗពោរពេញ ដោយកម្លាំងចិត្ត ក្តីសង្ឃឹម និងភាពប៉ិនប្រសប់ យ៉ាងរស់រវើកតាមសកម្មភាពនីមួយៗ។ ខ្លះលេងកីឡា បាលទាត់ ខ្លះវាយសី ខ្លះទាញព្រ័ត្រ និងលោតអន្ទាក់ជាដើម។ កុមារីរិទ្ធីសាមរី កំពុងតែចូលរួមលេងល្បែងកំសាន្តយ៉ាងសកម្មជាមួយមិត្តរបស់នាង។ នាងផ្អាកបន្តិចរួច ក៏និយាយដោយសំឡេងរីករាយថា : "នាងមានអារម្មណ៍រីករាយរំភើបណាស់ ដែលបានចូលរួមក្នុងកម្មវិធីសាំមើខេមនេះ ពីព្រោះនាងបានរៀនភាសាអង់គ្លេស គូរគំនូរ លេងល្បែង លេងកីឡា រៀនរាំរបាំ ហើយបានទៅកំសាន្តនៅកន្លែងមួយចំនួនទៀត មានពោធិ៍សាត់ ភ្នំសំពៅ ឬភ្នំបាណន់-ល-។" កុមារីនេះបន្ថែមថា មានអាហារគ្រប់គ្រាន់ ពេញ១ថ្ងៃ។ ប្អូនទទួលអង្ករ ២៥គក ទៀត នៅពលបិទកម្មវិធី។ ជាងនេះគឺប្អូនបានទទួលសម្ភារៈសិក្សា និងសម្លៀកបំពាក់សម្រាប់ការបើកបវេសនកាលថ្មីតែម្តង។ ចំពោះសកម្មភាពដ៏ប្រសើររបស់យុវជនអេស្ប៉ាញ និងកម្ពុជា ក្នុងកម្មវិធីផ្តល់អាហារូបត្ថម្ភដល់កុមារក្រីក្រ កំព្រា និងអនាថានេះ លោកបូជាចារ្យតូតែត តំណាងពេញសិទ្ធិនៃអភិបាលព្រះសហគមន៍កាតូ-លិក ភូមិភាគបាត់ដំបង មានប្រសាសន៍ថា : "នេះជាការគាំទ្រ និងអំណរសប្បាយ នៃព្រះសហគមន៍កាតូលិក ដែលក្រុមយុវជនអេស្ប៉ាញ បានមកចែករំលែកអំណោយទាន និងជីវិតរីករាយរបស់ពួកគេដល់កុមារកម្ពុជាយើង។ នេះក៏ជាឱកាសមួយដ៏ល្អដើម្បីឱ្យកុមារៗមានទំនាក់ទំនងជាមួយគ្នា នៅក្នុងសង្គម ពិសេសគឺទទួលនូវក្តីស្រលាញ់ពីអ្នកដ៏ទៃ។ លោកបូជាចារ្យរូបនេះ សង្កត់ធ្ងន់ថា : "កម្មវិធីនេះជាឱកាសសម្រាប់យុវជនកម្ពុជាក្នុងការរៀនទទួលខុសត្រូវ និងបង្ហាញឱ្យ យុវជនគេរៀនអំពីវប្បធម៌ និងទំនៀមទម្លាប់ខ្មែរយើងដែរ"៕

### គម្រោងការ

**សម្រាប់គម្រោងការក្នុងឆ្នាំខាងមុខ លោកហ្គុនសាឡូ ហ្វីហ្គារ៉េដូ (ភូមី) ជាអ្នកដឹកនាំក្រុមយុវជនអេស្ប៉ាញ បញ្ជាក់ថា លោកនឹងត្រលប់មកខេត្តបាត់ដំបងនេះនៅឆ្នាំក្រោយ ដើម្បីបន្តជួយផ្តល់សម្ភារៈសិក្សាអាហារូបករណ៍ដល់កុមារមួយចំនួនឱ្យបានចូលរៀន។ ហើយរាល់ការចំណាយក្នុងកម្មវិធីនេះ បានមកពីការឧបត្ថម្ភរបស់ប្រជាជនអេស្ប៉ាញ។**



យុវជនអេស្ប៉ាញចែកអំណោយដល់កុមារក្រីក្រ

Photo : L. Sovanna

September-2008.qxd 8/27/2008 9:44 AM Page 8



# CCAMH : ជួយកុមារមានបញ្ហាសុខភាពផ្លូវចិត្ត

**ឡុង សម្ផស្ស**


សកម្មភាពបង្រៀនកុមារមានបញ្ហាផ្លូវចិត្ត របស់មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ

អង្គការការីតាសកម្ពុជា គឺជាអង្គការអន្តរជាតិផ្នែកអភិវឌ្ឍន៍សង្គមរបស់ព្រះសហគមន៍កាតូលិក ដែលបានចាប់ផ្តើមសកម្មភាពនៅក្នុងប្រទេសកម្ពុជា នាឆ្នាំ១៩៩០។ អង្គការនេះគឺមានសកម្មភាពអភិវឌ្ឍសង្គមដោយមិនគិតពីជាតិសាសន៍ និងពណ៌សម្បុរឡើយ។ អង្គការលើកតម្កើងនូវសេចក្តីថ្លៃថ្នូររបស់ជនក្រីក្រ និងការគោរពសិទ្ធិមនុស្សដោយបានជួយអ្នកក្រីក្រ និងអ្នកដែលត្រូវបានគេ បោះបង់ចោលដោយផ្តោតចំពោះកម្មវិធីអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច អប់រំ វប្បធម៌ និងនយោបាយ។

អង្គការកំពុងធ្វើសកម្មភាព មាន ៥ផ្នែកសំខាន់ៗ: កម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះ កម្មវិធីអភិវឌ្ឍន៍វិស័យសុខភាព កម្មវិធីអភិវឌ្ឍន៍យុវជន ការអប់រំ និងការគ្រប់គ្រងគ្រោះមហន្តរាយ។

កម្មវិធីមួយកំពុងអនុវត្តន៍នៅក្នុងមន្ទីរពេទ្យបង្អែកជ័យជម្នះ ស្រុកតាខ្មៅ ខេត្តកណ្តាលនោះ ជាកម្មវិធីរបស់មជ្ឈមណ្ឌលសុខភាព ផ្លូវចិត្តកុមារ ហៅកាត់ **CCAMH**។នេះជាកម្មវិធីថ្នាក់ជាតិដើម្បីជួយដល់កុមារបញ្ញាអន់ខ្សោយ កុមារមានបញ្ហាលូតលាស់យឺតយ៉ាវ និងកុមារដែលមានបញ្ហាផ្លូវចិត្ត។

កម្មវិធីនេះបានយកចិត្តទុកដាក់ដើម្បីពង្រឹងស្ថាប័នកសាងសមត្ថភាពបុគ្គលិក ពង្រឹងការងារសហគមន៍ ហើយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដែលធ្វើការជាមួយកុមារផងដែរ។

កម្មវិធីនេះមានសកម្មភាព ៣ធំៗ: សកម្មភាពក្នុងមណ្ឌល សកម្មភាពក្នុងសាលារៀន និងសកម្មភាពនៅក្នុងសហគមន៍។ លទ្ធផលដែលទទួលបានកុមារដែលមានបញ្ញាអន់ខ្សោយចំនួន ៥២៧០នាក់មកពីគ្រប់ខេត្ត-ក្រុង បានទទួលសេវាព្យាបាល និងការថែទាំ។ ចំនួនកុមារដែលមានបញ្ហាផ្លូវចិត្ត ហើយបានចូលរៀននៅក្នុងសាលារដ្ឋមានការកើនឡើង។ គ្រូបង្រៀន ក៏កាន់តែមានការយល់ដឹង អំពីរបៀបជួយដល់កុមារទាំងនោះ នៅពេលដែលពួកគេ ជួបបញ្ហាផ្លូវចិត្ត។ សហគមន៍ក៏មានការយល់ដឹងច្រើនអំពីបញ្ហាផ្លូវចិត្តរបស់កុមារជាងមុន។

ហើយម្យ៉ាងទៀត សកម្មភាពនេះដែលអាចដំណើរការទៅបានប្រកបដោយភាពជោគជ័យនោះ ព្រោះមានការសហការពីសំណាក់ស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលដើម្បីបញ្ជូនកុមារ ដែលមានបញ្ហាផ្លូវចិត្តមកទទួលសេវាថែទាំ និងព្យាបាលដែរ៕

## “កូនខ្ញុំគ្រាន់បើជាងមុន ក្រោយពីទទួលសេវាថែទាំនៅទីនេះ”

នេះគឺជាប្រសាសន៍របស់អ្នកស្រីជាម្តាយរបស់ក្មេងស្រីម្នាក់ឈ្មោះស្រី នាថ អាយុ៧ឆ្នាំ សព្វថ្ងៃ កំពុងរស់នៅក្នុងសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ។

អ្នកស្រីរៀបរាប់ឱ្យដឹងថា កាលពីស្រីនាថ អាយុ ៣ ឆ្នាំ ថ្ងៃមួយនាងក្តៅខ្លួនយ៉ាងខ្លាំង ដែលបណ្តាលឱ្យនាងប្រកាច់ បាត់មាត់ បាត់ក ដែលធ្វើឱ្យខ្ញុំភ័យ ជាខ្លាំង និងនាំនាងទៅមន្ទីរពេទ្យ។ ចាប់តាំងពីពេលនោះមក កូនរបស់ខ្ញុំ នាងពុំអាចដើរបាន ឬនិយាយបានឡើយ។ ខ្ញុំព្យាយាមស្វះស្វែងរកពេទ្យជំនាញជាច្រើន ដើម្បីព្យាបាលនាង តែមិនបានធូរស្រាលសោះ។ តាមចាស់ៗនិយាយថា កូនខ្ញុំខុសនេះ ខុសនោះ តាមជំនឿអរូបីផ្សេងៗ។ ខ្ញុំព្យាយាមធ្វើតាម ប៉ុន្តែក៏នៅតែមិនគ្រាន់បើទេ។ ថ្ងៃមួយខ្ញុំបានទទួលដំណឹងពីមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារនេះ ខ្ញុំក៏បាននាំកូនមកកាន់ទីនេះ ហើយចាប់តាំងតែពីពេលនោះមក កូនខ្ញុំនាងបានគ្រាន់ជាងមុន។

អ្នកស្រីគូសបញ្ជាក់ថា កាលពីមុននាងមិនអាចដើរ


ស្រីនាថរូបក្មេងតូចខាងឆ្វេងបង្អស់

Photos : L. Samphors

បាន ប៉ុន្តែឥឡូវនាងអាចដើរបាន អាចលេងជាមួយក្មេងឯទៀតៗ និងស្គាល់មនុស្សទាំងអស់នៅក្នុងផ្ទះ ប៉ុន្តែគ្រាន់តែនាងមិនទាន់អាចនិយាយបានច្បាស់។

នៅទីនេះ មានផ្តល់នូវសេវាព្យាបាលជាច្រើនដូចជាផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល និងគ្រួសារ មានការព្យាបាលដោយលេងល្បែង ការព្យាបាលដោយធ្វើចលនារាងកាយ និងផ្តល់ឱសថព្យាបាលជាដើម។

ចាប់តាំងពីកូនរបស់ខ្ញុំ បានមកទទួលការព្យាបាលសុខភាពរបស់នាងបានល្អប្រសើរបន្តិចម្តងៗ ដែលធ្វើឱ្យខ្ញុំមានអំណរសប្បាយយ៉ាងក្រៃលែង។ហើយជារៀងរាល់ខែ ខ្ញុំត្រូវតែជូនស្រីនាថមកកាន់មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារនេះ ដើម្បីទទួលយកថ្នាំ និងសេវាពីកម្មវិធីនេះ៕






Photo : L. Sovanna

# យុវជនបួងសួងដល់ព្រះ គឺដើម្បីសុំសេចក្តីសុខ

**លី សុវណ្ណា**

សម្លេងពិណពាទ្យប្រគុំយ៉ាងរងំចេញពីប្រាសាទតូចមួយ ជាប់មាត់ទន្លេនៅខាងមុខព្រះបរមរាជវាំង។ នៅបរិវេណប្រាសាទតូចនេះ មានមនុស្សម្នា ក្មេងចាស់ ប្រុសស្រី ចេញចូលឥតដាច់ ខ្លះកាន់ផ្កាឈូក ធូប ទៀន ស្លាធ៌រ ឬក៏ដូងខ្ចី។ ចូលដល់មុខប្រាសាទម្នាក់ៗត្រូវតែដោះស្បែកជើងជាការគោរព រួចចូលទៅអុជធូប ដោតមុខរូបបដិមា ដែលនៅពីខាងក្នុងប្រាសាទនោះ ដែលគ្រប់គ្នាប្រសិទ្ធនាមថា ព្រះអង្គដងកើ។ ក្រោយដោតធូបបួងសួងហើយ ខ្លះសុំទឹកមន្តមកលប់លាងមុខ ហើយខ្លះទៀតយកទៅផ្ទះ។ បន្ទាប់ពីនេះអ្នកខ្លះមានចែកទានដល់អ្នកក្រីក្រនៅទីបរិវេណប្រាសាទនោះដែរ។

កញ្ញាស្រី រដ្ឋា ប្រាប់ឱ្យដឹងថា នាងតែងមកអុជធូបបួងសួងនៅមុខព្រះអង្គដងកើ ដើម្បីសុំសេចក្តីសុខ និងចែកទានដល់ចាស់ៗ ដែលអង្គុយសុំទាននៅបរិវេណនោះផង។ យុវតីរូបនេះក៏បន្តថា នាងគោរពដោយត្រាប់តាមទម្លាប់គ្រួសារនាង ដែលកាលនាងនៅពីតូច គ្រួសារតែងនាំនាងមកគោរព និងថ្វាយបង្គំព្រះអង្គនៅទីនេះ។ នាងមកជារៀងរាល់ខែ ឬបីអាទិត្យម្តង។ ពេលអុជធូប និងទទួលទឹកមន្ត ធ្វើឱ្យអារម្មណ៍នាងមានសេចក្តីសុខ និងរីករាយផង។ ដោយនាងជឿពិតថា ព្រះអង្គដងកើ ពិតជាជួយឃុំគ្រប់គ្រងនាងឱ្យបានសេចក្តីសុខ។

រីឯយុវជនលឹម គុណណោកា គឺជាពុទ្ធសាសនិកមួយរូបដែរនោះ បានឱ្យដឹងថា លោកមិនដែលទឹកចាប់អារម្មណ៍ អុជធូបបួងសួង នៅថ្ងៃសីល ឬក៏ទៅវត្តនោះទេដោយសារពេលវល់ពេក ធ្វើឱ្យភ្លេច។ តែយុវជនរូបនេះបញ្ជាក់ថា លោកតែងតែទៅសុំព្រះសង្ឃស្រោចទឹក មុនពេលលោកបំពេញកិច្ចការ ឬមុខជំនួញរបស់ខ្លួន។ ក្រោយពីពេលទទួលទឹកមន្តហាក់ដូចជាអារម្មណ៍ល្អ និងមានគំនិតដោះស្រាយបានយ៉ាងទូលាយ។ ចំពោះទ្រឹស្តី និងធម៌របស់ព្រះពុទ្ធបរមគ្រូ លោកនៅមិនបានស្វែងយល់ស៊ីជម្រៅនោះឡើយ។ លោកគ្រាន់តែដឹងថា ធ្វើល្អនឹងទទួលផលល្អតែប៉ុណ្ណោះ។

ចំណែកយុវជនរស់ ហុក បានបញ្ជាក់ផ្ទុយពីនេះថា លោកមិនដែលមានពេលអុជធូប ឬបួងសួងចំពោះមុខរូបបដិមា ឬព្រះវិហារណាមួយ សុំសេចក្តីសុខនោះឡើយ ព្រោះលោកមិនពេលវេលាគ្រប់គ្រាន់ ហើយលោកថា នេះជាជំនឿ “អរូបី”។ យុវជនរូបនេះមិនបដិសេធនូវជំនឿរបស់ដូនតានោះទេ ប៉ុន្តែប្រហែលមកពីរូបគេ ចាប់អារម្មណ៍លើផ្នែកវិទ្យាសាស្ត្រច្រើនពេក។ ទោះជាយ៉ាងណា លោកនៅតែជាពុទ្ធសាសនិកមួយរូប លោកមិនបោះបង់ឡើយ។ ព្រះរាជាណាចក្រកម្ពុជា បានទទួលស្គាល់ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា៤៣។ ការអប់រំទ្រឹស្តីនៃព្រះពុទ្ធសាសនា ក៏បានចាក់ឫសយ៉ាងជ្រៅក្នុងដួងចិត្តរបស់ជនជាតិខ្មែរគ្រប់រូប។ ទោះបីជាយ៉ាងនេះក្តីយុវជនមួយចំនួនបានសម្តែងនូវការខកចិត្ត ដោយពួកគេពុំបានទទួលទ្រឹស្តីនេះឱ្យទូលំទូលាយនៅឡើយ។

លោករស់ ហុក បានសម្តែងចេញអារម្មណ៍របស់ខ្លួនថា ការអប់រំអំពីពុទ្ធសាសនា គឺហាក់ដូចជាមិនទូលំទូលាយនៅឡើយ ពីព្រោះបើយុវជន អ្នកចង់ស្វែងយល់ពីទ្រឹស្តីព្រះពុទ្ធជ្រៅជ្រះ គេត្រូវតែបួសជាព្រះសង្ឃ។ យុវជនគុណណោកា ក៏យល់ស្របដូចគ្នាដែរ ដោយលោកបន្ថែមថា ពេលមានការចាក់ផ្សាយនូវធម្មទេសនាតាមវិទ្យុ និងទូរទស្សន៍ លោកក៏ទទួលបានការយល់ដឹងច្រើនអំពីសុជីវធម៌ ឬពីការគោរពឪពុកម្តាយ ចាស់ព្រឹទ្ធាចារ្យ-ល-។ ប៉ុន្តែទ្រឹស្តីព្រះពុទ្ធសាសនាមានគំនិតពិបាកយល់ច្រើនដែរ ដោយសារមិនសូវមានពាក្យសម្រាយដើម្បីឱ្យអ្នកធម្មតាងាយយល់ឡើយ។ លោកនិយាយថា បើអាចមានការពន្យល់សម្រាយច្រើនជាការល្អប្រសើរ។លោករស់ ហុក ក៏សំណូមពរថា សូមឱ្យបញ្ចូលកម្មវិធីព្រះពុទ្ធសាសនា ចូលទៅក្នុងកម្មវិធីអប់រំ ដើម្បីបានជាប្រយោជន៍ដល់យុវជន អាចស្វែងយល់ពីទ្រឹស្តីនេះឱ្យបានទូលំទូលាយ និងដើម្បីចូលរួមពង្រឹងគ្រឹះព្រះពុទ្ធសាសនានៅក្នុងចំណោមយុវជនខ្មែរយើងដែរ។ បើយុវជនយល់អំពីធម៌ព្រះពុទ្ធបានច្រើននោះ អំពើហិង្សាក្នុងសង្គម ក៏នឹងថយចុះដែរ៕

September-2008.qxd 8/27/2008 9:44 AM Page 10

## បទយកការណ៍

# ការប្រឡងមធ្យមសិក្សាទុតិយភូមិ និងបញ្ហាត្រូវដោះស្រាយ

ខាន់ ភីរម្យ

ដោយស្លៀកសម្លៀកបំពាក់ស្រស់ស្អាត ជាមួយនិងឯកសណ្ឋានសិស្ស ខោខៀវអាវស សម្រាប់យុវជន និងសំពត់ខៀវអាវស សម្រាប់យុវនារី បេក្ខជនខ្លះបានប្រើប្រាស់យានជំនិះខ្លួនឯង ហើយអ្នកខ្លះទៀតត្រូវបានសាច់ញាតិជូនមក នាំគ្នាសំដៅមកមណ្ឌលប្រឡង ពីរដង ក្នុងមួយថ្ងៃ គឺព្រឹក ពីម៉ោង៧:០០ និងរសៀល ចាប់ពីម៉ោង ១:៣០នាទី ជាប់ៗគ្នា ជាប្រចាំរយៈពេលពីរថ្ងៃកន្លះ។ ទាំងនេះគឺជាទិដ្ឋភាពតាមប្រក្រតី ដែលកើតមាននៅតាមបណ្តាមណ្ឌលប្រឡងសញ្ញាបត្រនៃមធ្យមសិក្សាទុតិយភូមិ ដែលក្រសួងអប់រំយុវជន និងកីឡា រៀបចំឡើង តាំងពីថ្ងៃទី៤ ដល់ថ្ងៃទី៦ សីហា កន្លងទៅនេះ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងទិដ្ឋភាពនេះ គេក៏សង្កេតឃើញមានបាតុភាពមិនប្រក្រតីមួយចំនួន កើតឡើងផងដែរ។

**ទិដ្ឋភាពទូទៅនៃការប្រឡង**

ទិដ្ឋភាពទូទៅខាងក្រៅមណ្ឌលប្រឡងទាំងឡាយ គឺប្រហាក់ប្រហែលគ្នា។ ការប្រឡង ត្រូវបានរៀបចំទាំងព្រឹក និងល្ងាច ដោយបេក្ខជនដែលត្រូវចូលរួមប្រឡងទាំងអស់ត្រូវមកជួបជុំគ្នា នៅម៉ោង ៧:០០ ព្រឹក និងនៅម៉ោង ១:០០ ពេលរសៀល តាមមណ្ឌលប្រឡងរយៈពេល២ថ្ងៃកន្លះ។

មុនពេល អាចចូលទៅក្នុងបរិវេណមណ្ឌលប្រឡងបាននោះ យុវសិស្សទាំងឡាយត្រូវប្រឈមមុខនឹងការឆែកឯកសារមួយដំណាក់។ នេះគឺជាហេតុធ្វើឱ្យយុវសិស្សមួយចំនួន ព្យាយាមលាក់ឯកសារលបមើល តាមរបង ពិសេសនៅកន្លែងផ្ញើម៉ូតូ ឬកន្លែងណា ដែលមានសភាពដូចជាបិទបាំងពីភ្នែកអនុរក្សបាន មុននឹងចូលទៅក្នុងបរិវេណមណ្ឌល ឬពេលខ្លះមានអ្នកហុចឯកសារឱ្យ ពេលចូលបរិវេណមណ្ឌលប្រឡងរួចរាល់ហើយនោះ។

បន្ទាប់នៅវេលាម៉ោងប្រមាណ ៧:៣០នាទី ក៏មានសំឡេងមេក្រូមួយបានបន្លឺឡើង: "លោកគ្រូអ្នកគ្រូទាំងអស់ដែលជាអនុរក្ស សូមប្រមូលយកឯកសារទាំងអស់ពីបេក្ខជន ពេលមកដល់មុខបន្ទប់។ សូមបញ្ជាក់! សូមដាក់សំណៅឯកសារទាំងអស់ពីក្រៅបន្ទប់ មិនមែននៅលើតុ ក្នុងបន្ទប់ប្រឡងឡើយ។ បេក្ខជនម្នាក់ៗអាចយកចូលបានតែប៊ិច ដែកឈាន និងខ្មៅដៃតែប៉ុណ្ណោះ"។ បន្ទាប់ពីនោះមក គេបានសង្កេតឃើញបេក្ខជនទាំងអស់ចូលក្នុងបន្ទប់ យ៉ាងស្ងាត់ស្ងៀម។ ហើយនៅខាងក្រៅរបងទ្វារមណ្ឌលប្រឡងនីមួយៗនោះ មានការឃាមកាមពីភ្នាក់ងារសមត្ថកិច្ច ហើយមិនមានបាតុភាពគប់ឯកសារចូលមណ្ឌលប្រឡងអនាធិបតេយ្យនោះទេ ប៉ុន្តែមណ្ឌលខ្លះ ក៏មានក្រុមយុវជន និងមនុស្សវ័យកណ្តាលមួយចំនួនប្រមូលគ្នាជុំៗនៅជុំវិញមណ្ឌលដែរ។

**មតិផ្សេងៗ ជុំវិញការប្រឡងសញ្ញាបត្រទុតិយភូមិ ថ្ងៃទី៤-៦ ខែសីហា ឆ្នាំ២០០៨**

លោករ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានមានប្រសាសន៍ថា ការរៀបចំសម្រាប់ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ កាលពីដើមខែសីហាកន្លងទៅ សមាគមរបស់លោក បានរកឃើញភាពមិនប្រក្រតីជាច្រើន ដែលវានឹងធ្វើឱ្យប៉ះពាល់ដល់ការរៀបចំការប្រឡងនិងគុណភាពនៃការអប់រំនៅប្រទេសកម្ពុជា។ លោកបន្តថា នៅក្នុងរយៈពេលប្រឡង តួយ៉ាងយើងបានរកឃើញ មានការប្រមូលលុយ ដើម្បីស៊ូកមេប្រយោគ ជាថ្នូរនឹងការអនុញ្ញាតឱ្យបើកចម្លងនូវឯកសារ មានការបែកធ្លាយវិញ្ញាសាមុនពេលប្រឡង និងមានការលួចធ្វើអត្រាកំណែឱ្យសិស្សជាដើម។

នេះជាអំណះអំណាង ដែលអះអាងដោយសមាគមគ្រូបង្រៀនឯករាជ្យ តែទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីក្រសួងអប់រំ ដែលមានឋានៈជានាយកសាលារៀនមួយរូបបានអះអាងថា ភាពមិនប្រក្រតីនេះគឺមិនមែនកើតមានគ្រប់តែមណ្ឌលប្រឡងនោះទេ គឺមានតែកន្លែងខ្លះប៉ុណ្ណោះ។

លោកសុខ សុវណ្ណា នាយកវិទ្យាល័យបាក់ទូក បានមានប្រសាសន៍ថា ភាពមិនប្រក្រតីពិតជាកើតមានឡើងខ្លះមែន ប៉ុន្តែវាមិនមែនកើតគ្រប់តែមណ្ឌលប្រឡងទាំងអស់នោះទេ។ នេះគឺជាចំណុចខ្វះខាតដែលក្រសួងកំពុងតែមានវិធានការណ៍ និងស្វែងរកយុទ្ធសាស្ត្រដោះស្រាយនាពេលខាងមុខ។ លោកក៏បញ្ជាក់ដែរថា: "មណ្ឌលល្អក៏មាន ចំណែកមណ្ឌលអាក្រក់ក៏មាន ហើយយើងក៏មានបុគ្គលិកល្អៗ និងបុគ្គលិកខ្វះការទទួលខុសត្រូវដែរ"។

យុវសិស្សសូកា(ឈ្មោះប្រឌិត) ជាបេក្ខជនប្រឡងនៅឯមណ្ឌលអនុវិទ្យាល័យហ៊ុនសែន បុរី ១០០ខ្នង រាជធានីភ្នំពេញ បានអះអាងថា ពួកគេបានធ្វើការប្រមូលប្រាក់តាមមុខវិជ្ជា ដោយឱ្យពី៥០០០ រៀល ទៅដល់ ១៥០០០រៀល ក្នុងម្នាក់ៗ ដើម្បីជូនឱ្យគ្រូអនុរក្សតាមបន្ទប់ ដើម្បីឱ្យពួកគាត់កុំចាប់ឯកសារបើកចម្លងរបស់ពួកគេ។

ចំណែកយុវសិស្សស្គមល្អិតម្នាក់ទៀត រដ្ឋា (ឈ្មោះប្រឌិត) បេក្ខជនប្រឡងនៅមណ្ឌលបាក់ទូក ក៏បាននិយាយថា: "ខ្ញុំសប្បាយណាស់ ព្រោះខ្ញុំអាចបើកមើលឯកសារបានច្រើន ហើយឯកសារដែលខ្ញុំយកចូលគឺត្រូវចំច្រើនដែរ"។

ងាកមើលម្នាក់ទៀត យុវសិស្សឈ្មោះដានី (ឈ្មោះប្រឌិត) ដែលជាបេក្ខជនប្រឡងនៅមណ្ឌលវិទ្យា-ល័យសន្ធរមុខ បានអះអាងថា ការប្រឡងនៅថ្ងៃទីមួយ រូបនាងមានសង្ឃឹមថា ជាប់១០០% ពីព្រោះឯកសារដែលបងប្រុសនាងខិតខំដើរទិញឱ្យនោះ វាត្រូវចំជាងពាក់កណ្តាលឯណោះ។

លោករ៉ុង ឈុន ក៏អះអាងទៀតថា ជាទូទៅដោយសារតែមានភាពពុករលួយក្នុងចំណោមមន្ត្រីខ្លះនៅក្រសួងអប់រំ យុវសិស្សកម្ពុជាកំពុងយកការប្រឡងរបស់ពួកគេ ទៅជាការចម្លងវិញ ហើយទៅថ្ងៃមុខប្រសិនបើមិនគិតគូរចំពោះបញ្ហានេះទេ នោះវានឹងប៉ះពាល់ដល់គុណភាពនៃការអប់រំ នៅក្នុងប្រទេស និងផ្តល់ផលប៉ះពាល់ជាច្រើនចំពោះសង្គម។ លោកបន្តទៀតថា ការបើកចម្លងនេះ គឺវាមានតាំងពីយូរយាណាស់មកហើយ តែវាទើបតែបានរីករាលដាលយ៉ាងខ្លាំងចាប់ពីឆ្នាំ២០០០មក។

លោកងួវ ប៉ោទី នាយកអនុវិទ្យាល័យទឹកល្អក់ មានប្រសាសន៍ថា តាមធម្មតាការលួចចម្លងមិនមែនជារឿងជាទូទៅនោះទេ។ ទង្វើនេះច្រើនកើតតែនៅក្នុងចំណោមសិស្សៗ ដែលមិនចូលសាលា និងរៀនខ្សោយប៉ុណ្ណោះ។ លោកបញ្ជាក់ថា: "ត្រីមានត្រកមាននាលិ មិនមែនខូចទាំងអស់នោះទេ"។

យុវសិស្ស ចេស្តា (ឈ្មោះប្រឌិត) បេក្ខជនប្រឡងនៅមណ្ឌលសាលាបឋមសិក្សានរោត្តមវិញ បានឱ្យដឹងថា គាត់ពិតជាបើកមើលខ្លះមែន ប៉ុន្តែមិនមែនបើកមើលទាំងអស់ឡើយ។ ចេស្តាបញ្ជាក់ថា: "ខ្ញុំបើកមើលតែមេរៀនខ្លះៗ តែមុខវិទ្យាសាស្ត្រ ដូចជា គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា បើកមើលម៉េចនឹងកើត? យ៉ាងច្រើនបានមើលត្រឹមរូបមន្ត"។

**ផលប៉ះពាល់ និងដំណោះស្រាយ**

លោករ៉ុង ឈុន បញ្ជាក់ថា ប្រសិនមិនដោះស្រាយទេ ទៅថ្ងៃអនាគត សង្គមខ្មែរនឹងជួបប្រទះនូវវិបត្តិនៃការអភិវឌ្ឍន៍ ពីព្រោះកង្វះខាតធនធានមនុស្សដែលមានគុណភាព ហើយពេលនោះភាពក្រីក្រនឹងនៅតែបន្ត។ លោកបញ្ជាក់ថា: "សង្គមមួយ ដែលអាចអភិវឌ្ឍរីកចម្រើនទៅបាន គឺលុះត្រាតែសម្បូរបញ្ញាជន ប៉ុន្តែបើសម្បូរតែអ្នកល្ងង់ៗ ការអភិវឌ្ឍន៍ទៅមុខមិនកើតទេ។ ការបើកចម្លងនេះកំពុងធ្វើឱ្យកើតមាននូវវប្បធម៌ចម្លង សម្រាប់ការប្រឡងនៅក្នុងប្រទេសកម្ពុជាហើយ"។ លោកក៏បន្ថែមថា ការអប់រំជាកត្តាគន្លឹះសម្រាប់វិស័យផ្សេងៗទាំងអស់។ ហេតុដូច្នេះរដ្ឋាភិបាលគួរតែយល់ពីចំណុចនេះ។

ផ្ទុយមកវិញ លោកសុវណ្ណា អះអាងថា ការចម្លងនៅពេលប្រឡងនិងក្នុងពេលសិក្សា គឺជាបាតុភាពមួយ ដែលក្រសួងអប់រំកំពុងយកចិត្តទុកដាក់បំផុត ដូច្នេះមានន័យថា រដ្ឋាភិបាលមិនមែនមិនរវល់រឿងនេះទេ វាគឺជាកិច្ចការដែលកំពុងដោះស្រាយ ដើម្បីឈានទៅលុបបំបាត់ភាពអសកម្មនេះចោលបាន។ លោកបញ្ជាក់ដែរថា: "កិច្ចប្រជុំវាយតម្លៃ និងរកយុទ្ធសាស្ត្រថ្មីៗ តែងកើតមានឡើង នៅរៀងរាល់ក្រោយពេលការប្រឡងនីមួយៗបានបញ្ចប់"៕



ការផ្ទៀងផ្ទាត់ឯកសារពីខាងក្រៅមណ្ឌលប្រឡង

Photo : L. Samphors

### ស្ថិតិសម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

**លោកច្រឹង លឹមស្រ៊ី ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ មានប្រសាសន៍ថា នៅឆ្នាំនេះ មានសិស្សានុសិស្សប្រមាណជិត ៨០០០០នាក់ បានចូលរួមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយដើម្បីធានាគុណភាពនៃការប្រឡង ក្រសួងអប់រំបានជ្រើសរើសបុគ្គលិកចំនួនប្រមាណជា ១០០០០នាក់ ឱ្យចូលរួមរៀបចំការប្រឡងនេះ។ យោងទៅតាមសេចក្តីប្រកាសរបស់ក្រសួងអប់រំយុវជន និងកីឡា បានឱ្យដឹងថា សម្រាប់ការរៀបចំប្រឡងសញ្ញាបត្រទុតិយភូមិឆ្នាំនេះ ក្រសួងរៀបចំឱ្យមានមណ្ឌលប្រឡងដល់ទៅ ១៣៩មណ្ឌល និងមានបន្ទប់រហូតដល់ទៅ ៣២២០បន្ទប់ នៅទូទាំងប្រទេស។**

### រដ្ឋាភិបាល និងការយកចិត្តទុកដាក់ចំពោះការប្រឡង

**លោកច្រឹង លឹមស្រ៊ី បានអះអាងប្រាប់អ្នកសារព័ត៌មានថា ដើម្បីធានាការប្រឡងឱ្យមានលក្ខណៈត្រឹមត្រូវ រដ្ឋាភិបាលបានចំណាយថវិកាចំនួនប្រហែលជា ៩០០០លានរៀល សម្រាប់រៀបចំការប្រឡងពីថ្ងៃទី៤ ដល់ថ្ងៃទី៦ សីហា ឆ្នាំ២០០៨នេះ សម្រាប់ទូទាំងប្រទេស។ លោកមានប្រសាសន៍បញ្ជាក់ថា បើគិតទៅរាជរដ្ឋាភិបាលកម្ពុជា បានចំណាយថវិកាប្រហែលជា ៣០ដុល្លារ សម្រាប់សិស្សម្នាក់ បន្ថែមទៅលើថវិកាចំនួន ១៥០០រៀល ដែលទទួលបន្ទុកដោយសិស្សម្នាក់ៗ សម្រាប់ការទិញសំណុំឯកសារនានាដើម្បីចុះឈ្មោះប្រឡង។ លោកបន្តថា បើតាមបទពិសោធន៍នៅបរទេសភាគច្រើន គឺរដ្ឋាភិបាលប្រទេសទាំងនោះ បានតម្រូវឱ្យសិស្សចេញលុយខ្លួនឯង លើការប្រឡងបែបនេះ ដើម្បីឱ្យពួកគេខិតខំរៀនសូត្រផង។ ប៉ុន្តែសម្រាប់នៅប្រទេសកម្ពុជា ដោយមើលឃើញការលំបាករបស់មាតាបិតាសិស្សនោះ រាជរដ្ឋាភិបាលបានសម្រេចចំណាយលើការងារនេះជំនួសពួកគេ។ លោកបន្តទៀតថា ការចំណាយប្រាក់នេះមិនមែនសម្រាប់ចំណាយលើសិស្សតែមួយមុខទេ គឺចំណាយសម្រាប់ការរៀបចំឯកសារនានា និងបុគ្គលិកក្រសួងអប់រំ ដែលជួយរៀបចំដំណើរការប្រឡងនេះដែលមានប្រមាណជា១០០០០នាក់ផងដែរ។**

September-2008.qxd 8/27/2008 9:45 AM Page 12

## កសិកម្ម

# ការធ្វើជីកំប៉ុស តាមបែបសាមញ្ញ

**ជាត សំភី**


Photo : L. Samphors
រោងឧទាហរណ៍សម្រាប់ធ្វើជីកំប៉ុស្ត

តាមប្រសាសន៍លោកគ្រុយ លឹមហួរ ជាអនុប្រធានស្ថានីយផលិតកម្ម និងស្រាវជ្រាវនៅឯសាលាជាតិកសិកម្មព្រែកលាប បានឱ្យដឹងថា វត្ថុធាតុសម្រាប់យកមកធ្វើជីកំប៉ុសនេះ គឺវត្ថុដែលអាចរលួយបាន មានរុក្ខជាតិគ្រប់ប្រភេទ ស្លឹកឈើជ្រុះ និងសំណល់ផ្ទះបាយ-ល- ហើយរបស់ដែលល្អបំផុតនោះ មានដូចជា រុក្ខជាតិទន្រ្ទានខេត្ត កន្ទំថេត បើរកមិនបានដាក់កំប្លោកក៏បាន ព្រោះរបស់ទាំងនេះសម្បូរជាតិអាសូតជួយដល់ការលូតលាស់របស់រុក្ខជាតិ។

ដើម្បីធ្វើកំប៉ុស កសិករត្រូវយកចិត្តទុកដាក់ ជ្រើសរើសទីកន្លែង កុំឱ្យលិចទឹក។ គាត់អាចសាងសង់ជាអាងដែលមានទំហំមួយម៉ែត្រគីប និងធ្វើជាដំបូលប្រក់កុំឱ្យជីកំប៉ុសត្រូវថ្ងៃ។ ដល់ពេលរៀបចំទីតាំងហើយ កសិករយកវត្ថុធាតុដើម មកចិញ្ច្រាំបញ្ចូលគ្នាឱ្យទៅជាទំហំតូចៗ យ៉ាងច្រើន ២ ទៅ៣ស.ម។ កសិករដាក់វាជាស្រទាប់ៗ។ តួយ៉ាងកន្ទំថេត អាចដាក់ស្រទាប់ទី១ កម្រាស់៥តឹក ស្រទាប់ទី២ ដាក់កំប្លោក ១០សម និងស្រទាប់ទី៣ កសិករអាចដាក់ទន្រ្ទានខេត្ត១៥សម ហើយទី៤កសិករដាក់រុក្ខជាតិផ្សេងៗទៀតក៏បាន ដូចជាដើមចេក ស្លឹកស្វាយ ឬស្លឹកទឹកដោះគោ... និយាយរួមគឺរុក្ខជាតិដែលងាយរកនៅក្នុងមូលដ្ឋាន។ បើមានរុក្ខជាតិតែ ៣ប្រភេទខាងលើ កសិករអាចដាក់សាចុះសាឡើង ដើម្បីឱ្យបានកម្ពស់អាង ១ម៉ែត្រ។ ចន្លោះស្រទាប់ៗកសិករដាក់អាចម៍គោ ផេះ អាចម៍មាន់ ឬកំបោរ ពីព្រោះសារធាតុទាំងនេះផ្តល់កម្តៅជួយបំប្លែងវត្ថុទាំងនេះឱ្យឆាប់ពុកផុយរលួយ។ នៅពេលរៀបចំរួចហើយ កសិករត្រូវស្រោចទឹក ជាន់ឱ្យហាប់ រកអ្វីមកគ្របឱ្យហាប់ ដូចជាស្លឹកដូង ឬកន្ទេល និងដោតបង្គោលឈើនៅចំកណ្តាលឱ្យកម្តៅភាយចេញ។ កសិកររង់ចាំពី៣០ ទៅ ៤០ថ្ងៃ រួចក៏រែងកំប៉ុសម៉ត់ វិចខ្ចប់ឱ្យស្រួលបួល និងទុកប្រើប្រាស់នៅពេលសមគួរ។

លោកគ្រុយ លឹមហួរ ក៏ផ្តល់អនុសាសន៍ដល់កសិករខ្មែរថា: "សូមឱ្យកសិករខ្មែរចាប់អារម្មណ៍ស្វែងរកបច្ចេកទេស និងធ្វើជីកំប៉ុស ដើម្បីប្រើប្រាស់ដោយខ្លួនឯង ព្រោះថា ការងារនេះ ទោះបីវានឿយបន្តិចមែន តែជួយឱ្យយើងចំណេញថវិកាច្រើនជាងការទិញជីគីមី។ ម្យ៉ាងទៀតការប្រើជីកំប៉ុសនេះ វានឹងផ្តល់ទិន្នផលប្រហាក់ប្រហែលនឹងជីគីមីដែរ តែមិនធ្វើឱ្យដីហិរ ខូច ប៉ះពាល់សុខភាព និងបរិស្ថានទៅថ្ងៃមុខទេ។ផ្ទុយមកវិញវាជួយកែប្រែដីដែលខូចរួចហើយឱ្យវិលមករកសភាពប្រក្រតីវិញបាន"៕

## បរិស្ថាន

### ទឹកខ្មេះឈើ

ទឹកខ្មេះឈើគឺជាវត្ថុរាវម្យ៉ាងពណ៌ត្នោត ដែលបានមកពីកំណកញើសនៅពេលផលិតធ្យូង។

**អត្ថប្រយោជន៍ទឹកខ្មេះឈើ**


Photo : geres

កែប្រែគុណភាពដី ធ្វើឱ្យដីធូរ និងមានជីជាតិល្អ។ បង្កើននូវការលូតលាស់ ភាពរឹងមាំ បរិមាណ និងគុណភាពលើទិន្នផលដំណាំ។ ការពារ-កាត់បន្ថយសត្វល្អិតចង្រៃ និងជំងឺដំណាំ។ ជួយពង្រឹងប្រព័ន្ធឫសរុក្ខជាតិឱ្យរឹងមាំ។ បង្កើននូវគុណភាពផ្លែ និងបន្ថែមជាតិស្ករចំពោះដំណាំឈើហូបផ្លែ។ ជំរុញឱ្យកំប៉ុសឆាប់រលួយ និងកាត់បន្ថយក្លិនពុំល្អ។ លាយជាមួយចំណីសត្វដើម្បីបង្កើនគុណភាពចិញ្ចឹម។

ដោយសិក្សាឃើញថា ទឹកខ្មេះឈើ មានប្រយោជន៍ជាច្រើន និងធំធេង ពិសេសលើវិស័យកសិកម្ម ទើប អង្គការ ក្រុមថាមពល កកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព (GERES Cambodia) បានសហការជាមួយនិង សមាគមអភិវឌ្ឍន៍ចម្រុះនៃសហគមន៍ព្រៃឈើ នៅស្រុកត្រាំកក់ ខេត្តតាកែវ រៀបចំកម្មវិធីមួយ ឈ្មោះថា "កម្មវិធីផលិតធ្យូងប្រកបដោយនិរន្តរភាព" ដែលស្របពេលជាមួយគ្នានេះ គេក៏អាចទាញបានផលបន្ទាប់បន្សំផ្សេងៗជាច្រើន ទៀតពីការផលិតនេះ គឺមានទឹកខ្មេះឈើជាដើម សម្រាប់ប្រើប្រាស់ជំនួសថ្នាំពុល និងជីគីមីក្នុងវិស័យកសិកម្ម។ ក៏សូមបញ្ជាក់ថា បច្ចេកទេសផលិត និងការត្រួតពិនិត្យគុណភាពទឹកខ្មេះឈើ គឺគ្រប់គ្រងដោយអង្គការ GERES Cambodia។ GERES Cambodia ផ្សព្វផ្សាយផលិតផល ទឹកខ្មេះឈើនេះ ចាប់តាំងពីឆ្នាំ ២០០៤ ដែលក្នុងនោះរួមមាន ទឹកខ្មេះឈើ ដែលត្រូវបានគេផលិតចេញពីដើមអាកាស្យា និងប្រេងខ្យល់៕



## សុខភាព

# កំណើនកូឡេស្តេរ៉ូលក្នុងឈាមបង្កគ្រោះថ្នាក់ភ្លាមៗ ដល់ស្លាប់

**ជាត សំភី**

លោកវេជ្ជបណ្ឌិតហែម សុខ ហន នៅឯមន្ទីរពេទ្យកុមារជាតិ មានប្រសាសន៍ថា:

កូឡេស្តេរ៉ូល ជាការបង្កើតឡើងដោយ ជាតិលីពីតដែលខ្មែរហៅថា ខ្លាញ់។ លីពីតនៅក្នុងខ្លួនមនុស្សបានមកពីប្រភពពីរ: ទីមួយ កើតចេញពីកោសិការបស់ថ្លើម ហើយទីពីរ គឺមានប្រភពពីចំណីអាហារដែលមនុស្សបរិភោគជារៀងរាល់ថ្ងៃ ដូចជា ខ្លាញ់របស់សត្វ ឬក៏ប្រេងរុក្ខជាតិជាដើម។

ដូច្នេះនៅពេលដែលយើងបរិភោគនូវ ចំណីអាហារដែលមានជាតិខ្លាញ់ច្រើនៗពេក នោះកូឡេស្តេរ៉ូលក្នុងខ្លួនក៏កើនឡើងច្រើនដែរ។ ហើយបើកាលណាកូឡេស្តេរ៉ូលកើនខ្ពស់នោះ វានឹងទៅកកជន់នៅក្នុងសរសៃឈាម ជាពិសេសសរសៃបេះដូង ដែលតាមធម្មតា គេហៅថាខ្លាញ់កកនៅក្នុងសរសៃបេះដូង។ នេះជាប្រការគ្រោះថ្នាក់ណាស់ព្រោះវាធ្វើឱ្យឈាមទៅចិញ្ចឹមបេះដូងមិនគ្រប់គ្រាន់។ អឺចឹងពេលខ្លះ អ្នកជំងឺឃើញមានសភាពធម្មតា តែស្រាប់តែគាត់ចុកដើមទ្រូងភ្លាមៗ ដោយកោសិកាបេះដូងខ្វះអុកស៊ីសែន ហើយស្លាប់ភ្លាមៗ។ ម្យ៉ាងពេលខ្លះទៀត ដុំកូឡេស្តេរ៉ូលតូចៗ ដែលរបកជ្រុះអាចទៅស្ទះសរសៃឈាមតូចៗណាមួយ ជាពិសេសសរសៃឈាមខួរក្បាល ក៏បណ្តាលឱ្យអ្នកជំងឺស្លាប់បានដែរ។ ម្យ៉ាងទៀតកំណើនកូឡេស្តេរ៉ូលនេះ ក៏ជាមូលហេតុសំខាន់នៃជំងឺលើសឈាម និងជំងឺទឹកនោមផ្អែមផងដែរ។

លោកវេជ្ជបណ្ឌិតហែម សុខ ហន បញ្ជាក់ថា ដើម្បីការពារគ្រោះថ្នាក់ បណ្តាលមកពីកូឡេស្តេរ៉ូលនេះ សូមយើងកុំបរិភោគនូវអាហារដែលមានជាតិសាច់ និងខ្លាញ់ច្រើនពេក មានជាអាទិ៍ដូចជា សាច់ជ្រូកបីជាន់ ពពួកស្បែកសត្វ មានស្បែកមាន់ ឬស្បែកទា និងអាហារប្រភេទចៀន ឬខ ពីព្រោះពួកវាសម្បូរកូឡេស្តេរ៉ូលណាស់។ យើងប្តូរមកបរិភោគអាហារប្រភេទចំហុយ ត្រី និងបន្លែផ្លែឈើឱ្យបានច្រើនវិញ


Photo : P. Samphy

ប្រសើរជាង។ ម្យ៉ាងទៀត សូមយើងហាត់ប្រាណឱ្យបានទៀងទាត់ ដើម្បីឱ្យខ្លួនប្រាណយើងចំណាយកូឡេស្តេរ៉ូលត្រឡប់ទៅវិញ។ យើងគួរហាត់ប្រាណឱ្យបានយូររយៈពេលមួយម៉ោង។ បើសិនជាមនុស្សវ័យចាស់ សូមធ្វើម្តងបន្តិចៗកុំបង្ខំ គឺរហូតដល់បានច្រើន រយៈពេលយូរ និងមិនត្រូវបង្ខំពេកទេ។

លោកវេជ្ជបណ្ឌិតសង្កត់ធ្ងន់ថា: "យើងគួរឱ្យពេទ្យជំនាញពិនិត្យសុខភាពរៀងរាល់ ៦ខែ ម្តង ពីព្រោះជួនកាលអ្នកស្គម ក៏មានកូឡេស្តេរ៉ូលកើនដែរ"៕

### អត្រាស្លាប់ដោយជំងឺអេដស៍សកលធ្លាក់ចុះ

របាយការណ៍មួយស្តីអំពីជំងឺអេដស៍នៅក្នុងឆ្នាំ២០០៨នេះ បង្ហាញថា ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍ នៅលើពិភពលោកសម្រាប់ឆ្នាំ២០០៧ បានធ្លាក់ចុះប្រមាណ ៧% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦។ អង្គការសហប្រជាជាតិទទួលបន្ទុកជំងឺអេដស៍ បានឱ្យដឹងនៅក្នុងរបាយការណ៍របស់ខ្លួនថា ក្នុងឆ្នាំ២០០៧ នេះ អត្រាស្លាប់របស់មនុស្សដោយសារជំងឺអេដស៍ មានត្រឹម ២លាននាក់ ប៉ុណ្ណោះ ខណៈដែលកាលពីឆ្នាំ២០០៦ មានចំនួន ២,២លាននាក់។ ចំណែកអត្រាឆ្លងវិញ ក៏មានការធ្លាក់ចុះដែរ គឺពី ៣លាននាក់ ក្នុងឆ្នាំ២០០៦ មកនៅត្រឹម ២,៧លាននាក់ ក្នុងឆ្នាំ២០០៧។ ប៉ុន្តែរបាយការណ៍នេះព្រមានថា ទោះបីជាចំនួនអ្នកឆ្លងមានការធ្លាក់ចុះមែន ប៉ុន្តែលើពិភពលោកទាំងមូលនេះ មានមនុស្សប្រមាណ ៣៣លាននាក់នៅក្នុងប្រទេសចំនួន ១៩៧ កំពុងរស់នៅមានផ្ទុកមេរោគអេដស៍៕

### មុងជ្រលក់ថ្នាំបន្ថយ អត្រាជំងឺគ្រុនចាញ់


Photo: DR

លោកវេជ្ជបណ្ឌិត ឌួង សុជាតិ ប្រធានមជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ បានអះអាងថា ចាប់ពីខែឧសភា ដល់ ខែវិច្ឆិកា គឺជាពេលដែលជំងឺគ្រុនចាញ់កំពុងតែរាតត្បាតខ្លាំង តែឆ្នាំនេះ មជ្ឈមណ្ឌលបានប៉ាន់ប្រមាណថា តួលេខនឹងធ្លាក់ចុះដោយសារការអនុវត្តកម្មវិធីជ្រលក់មុងការពារទទួលជោគជ័យ។ លោកបន្តទៀតថា សម្រាប់តួលេខ ៥ខែ នាដើមឆ្នាំ២០០៨នេះ កម្ពុជាទើបតែរកឃើញជំងឺគ្រុនចាញ់ចំនួន ១៩៥០០០ ករណីតែប៉ុណ្ណោះ ក្នុងនោះ មាន ៤៦នាក់ ប៉ុណ្ណោះដែលមានគ្រោះថ្នាក់ដល់ជីវិត។ លោកបញ្ជាក់ថា: "តួលេខនេះមានការធ្លាក់ចុះជិតពាក់កណ្តាល បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧"។

កម្ពុជាបានចាប់ផ្តើមនូវកម្មវិធីមុងជ្រលក់ថ្នាំដើម្បីការពារជំងឺគ្រុនចាញ់នោះជាច្រើនឆ្នាំហើយ ប៉ុន្តែវាទើបតែទទួលបានជោគជ័យនៅដើមឆ្នាំ២០០៨នេះប៉ុណ្ណោះ។ ផ្អែកតាមជោគជ័យនេះ អត្រារាតត្បាតជំងឺគ្រុនចាញ់នៅកម្ពុជារំពឹងថានឹងចុះច្រើន។

លោកឌួងសុជាតិ បញ្ជាក់ទៀតថា កាលពីពេលមុនយើងអនុវត្តកម្មវិធីមុងជ្រលក់ថ្នាំចេញពីក្រុង ប៉ុន្តែនៅពេលនេះយើងអនុវត្តនៅតាមសហគមន៍ ទើបយើងបានទទួលជោគជ័យយ៉ាងដូច្នេះ។ លោកបានអះអាងដែរថា: "ការបញ្ច្រាបនៅតាមសហគមន៍គឺជោគជ័យលឿនជាងធ្វើពីថ្នាក់ជាតិ"។

លោកបន្តទៀតថា ថ្នាំជ្រលក់មុងដើម្បីការពារជំងឺគ្រុនចាញ់នេះ គឺជាកម្មវិធីជ្រលក់ថ្នាំ ភីរីត្រ៉ូដ (Pyriphroide) ដែលជាប្រភេទថ្នាំសម្លាប់សត្វមូសដ៏មានប្រសិទ្ធភាពមួយ។

សូមបញ្ជាក់ថា សម្រាប់ប្រទេសកម្ពុជា ខេត្តដែលរងគ្រោះធ្ងន់ធ្ងរដោយសារជំងឺគ្រុនចាញ់ គឺខេត្តព្រះវិហារ សៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន កោះកុង និងខេត្តពោធិ៍សាត់។ ភ្នាក់ងារចម្លងមេរោគ គឺមូសដែកគោល៕

**ខាន់ ភិរម្យ**

September-2008.qxd 8/27/2008 9:45 AM Page 14





Photo : DR

# ភ្លេងពិណពាទ្យ នឹងមានគ្រោះថ្នាក់ ប្រសិនបើគ្មានការអភិរក្ស

ខាន់ ភិរម្យ

អ្នកអភិរក្សវប្បធម៌មួយរូបបានអះអាងថា ភ្លេងពិណពាទ្យជាភ្លេងបុរាណមួយ ជាឫសគល់នៃវប្បធម៌ខ្មែរ គឺកំពុងប្រឈមមុខនឹងគ្រោះថ្នាក់ ប្រសិនបើមិនមានការការពារ និងអភិរក្សថែរក្សាទេនោះ។

លោកសេក សុភា ជំនួយការប្រធានសមា-គមអភិរក្សសិល្បៈ និងវប្បធម៌ និយាយថា ភ្លេងពិណពាទ្យ ជាប្រភេទវង់ភ្លេងបុរាណមួយ ដែលអាចប្រគំឡើង ដោយប្រើប្រាស់ឧបករណ៍តន្ត្រីបុរាណខ្មែរ ជាច្រើនប្រភេទ មានគងតូច គងធំ ស្គរតូច ស្គរធំ រនាដដែក រនាដធំ ស្រឡៃតូច ស្រឡៃធំ ទ្រ ឬសំភោជាដើម។ ប៉ុន្តែនៅពេលនេះ ពិបាករកអ្នកដែលចេះលេងណាស់ ហើយក្មេងៗ មិនសូវមានចំណង់ចំណូលចិត្តរៀនប៉ុន្មានឡើយ។

លោកបានបន្តទៀតថា រហូតមកដល់ពេលនេះ សមាគមរបស់លោកកំពុងតែធ្វើកិច្ច-ការអភិរក្សនូវសិល្បៈនេះ ហើយក៏បានដើរប្រមូលក្មេងៗក្រីក្រមករៀន និងមិនតម្រូវឱ្យពួកគេបង់ប្រាក់អ្វីដែរ ប៉ុន្តែមានអ្នកមកចុះឈ្មោះដ៏តិចតួចបំផុត។ ដូច្នេះដើម្បីរក្សានូវប្រភេទភ្លេងនេះឱ្យគង់វង្សនោះ កិច្ចការអភិរក្សគួរតែត្រូវយកចិត្តទុកដាក់។

លោកបញ្ជាក់ផងថា៖ "កុំថាឡើយទៅដល់រៀនបង់លុយ សូម្បីតែយើងប្រមូលក្មេងៗមករៀនដោយមិនត្រូវការបង់លុយនោះ ក៏មិនសូវមានក្មេងមកចុះឈ្មោះដែរ"។

លោកក៏បន្តទៀតថា រវាងភ្លេងបុរាណ និងភ្លេងសម័យ យុវជនសម័យនេះ គឺគេនិយមចូលចិត្តដល់ភ្លេងសម័យជាង ដោយសារគេគិតថា វាងាយរៀន និងក៏ស្រួលរកការងារធ្វើបានងាយជាងភ្លេងបុរាណ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ លោកបានអះអាងថា ភ្លេងបុរាណ ជាពិសេស ពិណពាទ្យ ប្រសិនបើពួកគេចេះឱ្យស្ទាត់ជំនាញនោះ ពួកគេក៏ងាយស្រួលរកការងារធ្វើដែរ។ ម្យ៉ាងភ្លេងពិណពាទ្យក៏អាចយកមកលេងលាយគ្នាជាមួយ និងឧបករណ៍ភ្លេងសម័យបានដែរ ឱ្យតែយើងចេះកែច្នៃវានោះ។

លោកបន្តទៀតថា ភ្លេងពិណពាទ្យនេះគឺជាប្រភេទភ្លេងបុរាណមួយ ដែលគេអាចលេងនៅតាមពិធីបុណ្យប្រពៃណីនានា ហើយគេត្រូវការតន្ត្រីករពី ៨នាក់ ទៅ១០ ឬក៏១២នាក់ នៅពេលប្រគំម្តងៗ។ លោកសុភាបានបញ្ជាក់ថា៖ "បើលេង៨នាក់ គេហៅថាវង់តូច តែបើការប្រគំមានគ្នា ចាប់ ពី១០នាក់ដល់១២នាក់ គេហៅថាវង់ធំ"៕

អំណាន

## យើងទៅទស្សនាសារមន្ទីរជាតិ




សៀវភៅសរសេរ មានអត្ថបទខ្លីៗច្បាស់ៗ ស្រួលអាន ងាយយល់ ប្រើភាសាសាមញ្ញអមទៅដោយរូបថត និង រូបគូរយ៉ាងប្រណីត ដើម្បីជួយយុវជន ក្នុងការស្វែងយល់ពីវប្បធម៌ និងប្រវត្តិសិល្បៈខ្មែរ ចាប់តាំងពីសម័យបុរេប្រវត្តិដល់សតវត្សទី២០ នៃគ.ស។ ជាមួយសៀវភៅនេះ យើងក៏ហាក់ដូចជាបានដើរទស្សនាសារមន្ទីរជាតិដោយមានមគ្គុទ្ទេសក៍ម្នាក់ជួយពន្យល់។ រូបត្រូវគេអធិប្បាយ តាមលំដាប់អាយុកាល ទំនោរសាសនាព្រមទាំងទេវកថាដែលមានឥទ្ធិពលលើប្រជាជនខ្មែរ។

**"យើងទៅទស្សនាសារមន្ទីរជាតិ"** បង្ហាញពីអ្វីដែលយើងមើលនឹងភ្នែកទទេមិនឃើញ មានដូចជា (ប្រវត្តិកាល និងការវិវត្តរបស់រូប រឿងនិទានផ្សេងៗដែលទាក់ទងទៅនឹងរូបនីមួយៗរបៀបផលិត និងប្រើប្រាស់វត្ថុមួយចំនួន...)។ នៅទំព័រខាងចុង មានការពន្យល់ពីការជួសជុលរូបបដិមាផែនទីវត្ថុបុរាណ និងលំដាប់កាលប្រវត្តិចម្បងៗ ប្រទេសខ្មែរទៀតផង។ សៀវភៅនេះនិពន្ធរួមគ្នាដោយ ស៊ុនហេង ម៉េងឈាង និងម៉ារី កៃយ៉ា បោះពុម្ពនៅឆ្នាំ២០០៨ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយ SIPAR/ តំលៃ ៤០០០៛។

## អ៊ុយលីសវិលវិញ




អ៊ុយលីសវិលវិញ (អូឌីស្សេ) គឺជាស្នាដៃដ៏ឆ្នើមទី២នៃកវីអូមែរ ដែលប្រជាជនក្រិចនិទានតៗគ្នា ជារៀងរហូតមកតាំងពីសតវត្សរ៍ទី៩ និងទី៨ មុនគ.ស និងជះឥទ្ធិពលយ៉ាងខ្លាំងក្លាលើអក្សរសាស្ត្រ-វប្បធម៌អឺរ៉ុបរហូតដល់សព្វថ្ងៃ។ អ៊ីលីយ៉ាដ និងអូឌីស្សេ គឺសុទ្ធតែជារឿង ដែលទាក់ទងនឹងវីរកម្មរបស់មេទ័ពក្រិកក្នុងមហាចម្បាំងនៅទីក្រុងត្រ័រ។ អ៊ុយលីស ជាភាសារ៉ូម៉ាំងក្លាយមកពីភាសាក្រិច អូឌីស្សេ-អ៊ុសមានន័យថា "ឥតនរណា"។ វីរជនអ៊ុយលីស ចូលរួមច្បាំងដណ្តើមក្សត្រីអេឡែន ជាមហេសីនៃក្សត្រាមេណេ-ឡាសពីការជម្រត់របស់ប៉ារីស ដើម្បីយកទៅទីក្រុងត្រ័រ។ ដោយសារប្រាជ្ញាភាពអង់អាចក្លាហាន អ៊ុយលីសក៏ទទួលជ័យជម្នះ។ ពេលធ្វើដំណើរត្រឡប់មកប្រទេសវិញ អ៊ុយ-លីស ត្រូវឆ្លងកាត់ឧបសគ្គគ្រប់បែបយ៉ាងតាមសមុទ្រ និងកំហឹងអាទិទេពប៉ូស្ហេអ៊ីដុង ដែលតាមព្យាបាទ។ រឿងនេះបកប្រែជាភាសាខ្មែរដោយលោក ទត់ ពុទ្រី និងបោះពុម្ព នៅឆ្នាំ២០០៤ ដោយបណ្ណាគារអង្គរ៕

ហួត សុជាតា





# អ៊ីរ៉ាក់ ៖ សង្គ្រាមដែលអូសបន្លាយគ្មានទីបញ្ចប់

អាន ឡូរ៉ំ ប៉ូវ៉េ



មកទល់ពេលនេះ អស់រយៈពេលជាង ៥ឆ្នាំ ហើយដែលជារៀងរាល់ថ្ងៃ ជនជាតិអ៊ីរ៉ាក់បានរស់នៅក្នុងភ្លើងសង្គ្រាម។ តើការបោះឆ្នោតដើម្បីជ្រើសរើសប្រធានាធិបតី នៅសហរដ្ឋអាមេរិកថ្មី នៅខែវិច្ឆិកាខាងមុខនឹងផ្លាស់ប្តូរស្ថានភាពរបស់ពួកគេបានដែរឬទេ? បេក្ខជននៃគណបក្សប្រជាធិបតេយ្យដើម្បីចូលក្នុងសេតវិមាន លោកបារ៉ាក់ អូបាម៉ា ហាក់ចង់បញ្ចប់ ដោយចាកចេញពីសង្គ្រាមនេះ ដែលលោកបានវិនិច្ឆ័យថា "ការល្ងង់ខ្លៅ" និង "គ្មានប្រយោជន៍" ដែលផ្ទុយអំពីគូបដិបក្ខរបស់លោកមកពីគណបក្សសាធារណរដ្ឋ គឺលោក ចន ម៉ាកខេន។

បើតាមរយៈកាលប្រវត្តិកន្លងមក សហរដ្ឋអាមេរិកចក្រភពអង់គ្លេសជាសម្ព័ន្ធមិត្ត រួមនិងការពួតដៃពី ៤៨ប្រទេស ផ្សេងទៀត បានចាប់ផ្តើមនូវសង្គ្រាមប្រឆាំងអ៊ីរ៉ាក់ តាំងពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដោយបានប្រកាសជាផ្លូវការ ដើម្បីប្រយុទ្ធប្រឆាំងនឹងភេរវកម្ម (ពួកគេចោទប្រកាន់អ៊ីរ៉ាក់ថា គាំទ្រក្រុមអែកៃដា) ដើម្បីបំផ្លាញអាវុធប្រល័យលោក និងរំលំរបបផ្តាច់ការរបស់ លោកសាដាម ហ៊ូសេន ដែលបានគ្រប់គ្រងប្រទេសនេះ តាំងពីឆ្នាំ១៩៧៩។ នៅពីក្រោយនៃការបង្ហាញកម្លាំងនេះ សហគ្រាសអាមេរិកាំងខ្លះ បានទទួលផលប្រយោជន៍ពីការលក់អាវុធ និងការពារបាននូវផលប្រយោជន៍របស់ពួកគេពីការរកស៊ីប្រេងនៅក្នុងប្រទេសអ៊ីរ៉ាក់ ដែលជាផលិតករប្រេងធំទីពីរនៅក្នុងពិភពលោក។ គេបានប្រមើលមើលថា ការសង្ស័យទៅលើអាវុធប្រល័យលោក ត្រូវបានគេទទួលស្គាល់ថា នេះជាការកុហកមួយនាពេលក្រោយមក។

សង្គ្រាមនេះចាប់ផ្តើមឡើងតាមរបៀបសាមញ្ញ៖ មានការទម្លាក់នូវគ្រាប់បែក និងសមរភូមិប្រយុទ្ធ និងកងទ័ពថ្មើរជើងជាដើម។ យ៉ាងរហ័ស! របបនៃលោកសាដាម ហ៊ូសេន ដួលរលំ ការតាមប្រមាញ់អ្នកទទួលខុសត្រូវសំខាន់ៗ របស់អ៊ីរ៉ាក់ ក៏បានចាប់ផ្តើម។ អតីតមេដឹកនាំរបស់អ៊ីរ៉ាក់ (លោកសាដាម ហ៊ូសេន) ត្រូវបានចាប់ខ្លួនខែធ្នូ ឆ្នាំ២០០៣ ហើយត្រូវគេព្យួរក នៅបីឆ្នាំក្រោយមក បន្ទាប់ពីដំណើរការសាលាក្តីមួយមក។ ប្រធានាធិបតីអាមេរិកចចដាប់ប៊ិលយូ ប៊ូស ក៏ធ្លាប់បានប្រកាសថា នឹងបញ្ចប់សង្គ្រាមនាថ្ងៃទី១ ឧសភា ឆ្នាំ២០០៣។ ប៉ុន្តែតាមសភាពពិត កងកម្លាំងទ័ពបានផុងខ្លួននៅក្នុងជម្លោះរួចទៅហើយ។ ពួកគេត្រូវប្រឈមមុខទៅនឹងការបដិសេធពុំទទួល និងការតស៊ូរបស់ប្រជាជន ដែលជារឿយៗ ធ្វើនៅក្រោមទម្រង់ជាកម្លាំងឧទ្ទាម។

រដ្ឋបាលបណ្តោះអាសន្នមួយ ដែលទទួលយកដោយសហរដ្ឋអាមេរិក ត្រូវបានបង្កើតឡើង។ ការវាយប្រហារអត្តឃាត បានរីកដុះដាលដូចផ្សិត រួមទាំងការចាប់ជាចំណាប់ខ្មាំងផងដែរ។

រដ្ឋាភិបាលជំនួសថ្មីមួយ បានគ្រប់គ្រងអំណាចចាប់ពីដំណាច់ខែមិថុនា ឆ្នាំ២០០៤ហើយទទួលខុសត្រូវសម្រាប់រៀបចំនូវការបោះឆ្នោត ដើម្បីជ្រើសរើសមេដឹកនាំថ្មី។ ហើយកាលពីឆ្នាំ២០០៤ ក៏មានរឿងអាស្រូវមួយនៅគុកអាប៊ូ រ៉ៃអ៊ីបផងដែរ៖ ខ្សែភាពយន្ត ដែលបានបង្ហាញអំពីការប្រព្រឹត្ត មិនគប្បី ដែលធ្វើឡើងដោយទាហានអាមេរិក ទៅលើអ្នកទោសអ៊ីរ៉ាក់ ត្រូវបានគេផ្សព្វផ្សាយពាសពេញពិភពលោក និងទទួលរងការរិះគន់។

នៅក្នុងសង្គ្រាមអ៊ីរ៉ាក់នេះ អ្នកស្លាប់ និងរបួស មានចំនួនរាប់សិបពាន់នាក់ មានទាំងជនជាតិអ៊ីរ៉ាក់ និងជនជាតិអាមេរិក។ រីឯជនភៀសខ្លួនអ៊ីរ៉ាក់ទៅកាន់ប្រទេសជិតខាង គឺបានកើនឡើងលើសពី ២លាន-នាក់។ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លិចបំផ្លាញអស់ជាច្រើន។ ជម្លោះសាសនាក៏បានចាប់ផ្តើមដុះដាលឡើងវិញជាខ្លាំង ដែលជំរុញជាសង្គ្រាមស៊ីវិល។ ពិតមែន! ឥឡូវប្រទេសអ៊ីរ៉ាក់មានរដ្ឋធម្មនុញ្ញមានសភាជាតិ និងរដ្ឋាភិបាល ប៉ុន្តែប្រទេសនេះស្ថិតនៅឆ្ងាយពីការរកឃើញមកវិញនូវសន្តិភាព ទោះបីជាអាណត្តិនៃកងកម្លាំងសម្ព័ន្ធមិត្តថា នឹងចាកចេញពីអ៊ីរ៉ាក់នៅដំណាច់ឆ្នាំ២០០៨ ក៏ដោយ៕

## ភាពតានតឹងនៅតាមព្រំដែន



Photos : DR

**ចាប់តាំងពីផ្ទុះសង្គ្រាម ប្រទេសអ៊ីរ៉ង់ និងប្រទេសទួរគីបានកេងយកចំណេញពីអស្ថេរភាពផ្ទៃក្នុងនៅក្នុងប្រទេសអ៊ីរ៉ាក់ ដើម្បីព្យាយាមដោះស្រាយដោយហិង្សាចំពោះបញ្ហារបស់ពួកគេចំពោះប្រជាជនគួដ៍ ដែលបានផ្តល់ជាទីជម្រកឱ្យអ្នកទាមទារឯករាជ្យភាព និងសកម្មជនឧទ្ទាមដែលប្រឆាំងនឹងរដ្ឋាភិបាលនៃប្រទេសទាំងពីរនេះ។ ដូច្នេះជនជាតិអ៊ីរ៉ាក់ដើមកំណើតគួដ៍ ដែលមានរដ្ឋាភិបាលស្វយ័តមួយ បានក្លាយជាគោលដៅវាយប្រហារដោយយោធា។**




សូមថ្លែងអំណរគុណដល់អង្គការស៊ីប៉ាដែលជួយឧបត្ថម្ភទំព័រនេះ។

អង្គការស៊ីប៉ា : ប្រអប់សំបុត្រ ៣១ ផ្ទះលេខ៩ ផ្លូវ២១ រាជធានីភ្នំពេញ_កម្ពុជា ឬទូរស័ព្ទ : ០២៣ ២១៦ ០០១។

# សេចក្តីជូនដំណឹង !

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក
នឹងមានរៀបចំការប្រឡងប្រជែងខាងគូរគំនូរ
លើប្រធានបទអំពី "សិទ្ធិកុមារ" ។
លក្ខខណ្ឌចូលរួមប្រឡង : កុមារគ្រប់ៗរូប ដែល
មានអាយុពី ៨ឆ្នាំ ទៅដល់១៦ឆ្នាំ ។
សូមប្អូនៗផ្ញើគំនូរមកកាន់អាសយដ្ឋានការិយាល័យយើង
ឬតាមរយៈលោកឪពុក ឬបងស្រីដែលនៅជិតបំផុត
ឱ្យបានមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ ខាងមុខនេះ ។

# ការងារប្រចាំខែ

- នៅដើមខែកញ្ញាខាងមុខនេះ : ក្រុមបងស្រីដូមីនិកកាំង ដែលមានសមាជិកចំនួន ១៥នាក់ ធ្វើការស្ម័គ្រចិត្តរស់នៅផ្ទាល់ជាមួយអ្នកភូមិនៅក្រុងព្រះសីហនុ រយៈពេលមួយខែ។
- ថ្ងៃទី២ កញ្ញា : លោកបូជាចារ្យក្នុងភូមិភាគភ្នំពេញ មានជួបប្រជុំជាមួយលោកអភិបាល អេមីល ដេតម្ប នៅគេហដ្ឋានរបស់លោក។
- ថ្ងៃទី២-៥ កញ្ញា : សន្និបាតនៃយុវជនរៀបចំធ្វើនៅព្រះសហគមន៍កាតូលិកបាត់ដំបង ក្រោមប្រធានបទ "អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលនឹងមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ"។
- ថ្ងៃទី៦-៨ កញ្ញា : មានការជួបប្រជុំគ្នារបស់ក្រុមអេម៉ាណូអែលនៅព្រះសហគមន៍កំពង់ធំ។
- ថ្ងៃទី៨-១៤ កញ្ញា : ការប្រជុំ ឬការណែនាំដល់គ្រូអប់រំជំនឿនៅព្រះសហគមន៍បាត់ដំបង ដែលមានអ្នកចូលរួមចំនួន ៦០នាក់។
- ថ្ងៃទី១១-១៤ កញ្ញា : មានការរៀបចំការប្រជុំ ឬណែនាំដល់គ្រូអប់រំបន្តជំនឿ ប្រារព្ធនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី១៥-១៩ កញ្ញា : ការប្រជុំ Signis Assembly ធ្វើនៅការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ក្រោមប្រធានបទ "កុមារ និងប្រព័ន្ធផ្សព្វផ្សាយ"។
- ថ្ងៃទី១៦-២១ កញ្ញា : ដំណើរកិច្ចប្រជុំរបស់លោកបូជាចារ្យអ៊ុន សុន ហើយនិងលោកបូជាចារ្យម៉ារីយ៉ូនៅប្រទេស ស៊ីរីលង្កា ដែលស្តីអំពីប្រធានបទ លក្ខណៈពិធីបុណ្យតាមបែបកាតូលិកនៅប្រទេសកម្ពុជា។
- ថ្ងៃទី១៨-២០ កញ្ញា : សន្និបាតក្រុមសង្គហៈភូមិភាគភ្នំពេញ រៀបចំធ្វើឡើងនៅព្រះសហគមន៍ សន្តយ៉ូសែប។
- ថ្ងៃទី១៨-២៥ កញ្ញា : សិក្ខាសាលាការ៉ូ និងសេដ្ឋា សម្រាប់យុវជននៅកំពង់ចាម ដែលមានអ្នកចូលរួមចំនួន ៦០នាក់។
- ថ្ងៃទី១៩ កញ្ញា : ពិធីចែកអំណោយដល់គ្រួសារក្រីក្រចំនួន ១០០ គ្រួសារនៅព្រះសហគមន៍សន្តយ៉ូសែបសម្រាប់ឱកាសពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ។
- ថ្ងៃទី២៣ កញ្ញា : លោកបូជាចារ្យទាំងអស់ភូមិភាគភ្នំពេញ ធ្វើពិធីសំណាក់ធម៌នៅព្រះសហគមន៍សន្តយ៉ូសែប។